# សេចក្តីវិភាគផ្នែកសិទ្ធិមនុស្ស

# នៃវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ (២០១៧)

រៀបចំឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជា

ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧

## មាតិកា


I. **សេចក្តផ្តើម** ........ 2

II. **ការរឹតត្បិតដែលអនុញ្ញាតលើសិទ្ធិមនុស្ស** ........ 12

III. **សេចក្តវិភាគលើច្បាប់ស្តីពីគណបក្សនយោបាយ** ........ 16

មាត្រា៥.- ........ 16

មាត្រា៦.- ថ្មី ........ 16

មាត្រា៧.- ........ 18

មាត្រា៩.- ........ 18

មាត្រា១០.- ........ 19

មាត្រា១២.- ថ្មី ........ 20

មាត្រា១៥.- ........ 21

មាត្រា១៧.- ថ្មី ........ 22

មាត្រា១៨.- ថ្មី ........ 23

មាត្រា១៩ ថ្មី ........ 30

មាត្រា២៥.- ថ្មី ........ 34

មាត្រា២៩.-ថ្មី ........ 36

មាត្រា៣៤.-ថ្មី ........ 38

មាត្រា៣៨.- ថ្មី ........................................................................................................ 39
មាត្រា៤០.- ថ្មី ........................................................................................................ 41
មាត្រា៤១.- ថ្មី ........................................................................................................ 42
មាត្រា៤២.- ថ្មី ........................................................................................................ 43
មាត្រា៤៣.- ថ្មី ........................................................................................................ 44
មាត្រា៤៤.- ថ្មី ........................................................................................................ 44
មាត្រា៤៥.- ថ្មី ........................................................................................................ 45
មាត្រា៤៨.- ថ្មី ........................................................................................................ 46
មាត្រា៤៩.- ថ្មី ........................................................................................................ 47
មាត្រា៥០.- ថ្មី ........................................................................................................ 48

# I. សេចក្តីផ្តើម

សេចក្តីវិភាគនេះ ត្រូវបានផ្តួចផ្តើមធ្វើឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជា ដែលជាការរួមចំណែកមួយដល់ការពិនិត្យពិចារណាលើការធ្វើវិសោធនកម្មមួយចំនួន ដែលបានស្នើឡើងចំពោះច្បាប់ស្តីពីគណបក្សនយោបាយ។ ដោយសារតែការអនុម័ត និងការប្រកាសឲ្យប្រើមានលក្ខណៈឆាប់រហ័សពេកនូវសេចក្តីស្នើវិសោធនកម្មច្បាប់នេះដោយការប្រកាស "ជាការប្រញាប់" បានធ្វើឲ្យសេចក្តីវិភាគនេះ មិនអាចត្រូវបានសរសេរបញ្ចប់ទាន់ពេលវេលា សម្រាប់ដាក់ជូនពិនិត្យពិចារណាដោយស្ថាប័នដែលទទួលខុសត្រូវ ដើម្បីពិនិត្យ និងអនុម័តសេចក្តីវិភាគនេះ ក្នុងនោះរួមមាន រដ្ឋសភា ព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញ។ ប៉ុន្តែទោះជាដូច្នេះក្តី ការិយាល័យOHCHR សូមផ្តល់នូវសេចក្តីវិភាគរបស់ខ្លួនដោយក្តីសង្ឃឹមថានៅឱកាសក្រោយៗទៀត អាចនឹងធ្វើឲ្យច្បាប់នេះកាន់តែខិតជិតទៅរកអនុលោមភាពជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ។ សារៈសំខាន់នៃការធ្វើដូច្នេះ កើតចេញពីភាពជាប់ជំពាក់ដោយផ្ទាល់របស់ច្បាប់នេះទៅនឹងលទ្ធភាពរបស់ប្រជាពលរដ្ឋកម្ពុជា ក្នុងការអនុវត្តពេញលេញនូវសិទ្ធិមនុស្សរបស់ខ្លួន ជាពិសេសសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ ដែលត្រូវបានធានាការពារដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិ

មនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ហើយដែលសន្ធិសញ្ញាទាំងពីរនេះ ត្រូវបានចែងទទួលស្គាល់ក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា សម្រាប់អនុវត្តនៅប្រទេសកម្ពុជា។

ការប្រើប្រាស់ប្រកបដោយអត្ថន័យនូវសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ តម្រូវឲ្យមានការប្រើប្រាស់ផងដែរនូវសិទ្ធិដទៃផ្សេងទៀតដែលបានកំណត់ រួមទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ ការជួបប្រជុំ ការចូលរួម/បង្កើតសមាគម ការការពារមិនឲ្យមានការរើសអើង សិទ្ធិអប់រំ និងសិទ្ធិទទួលបានព័ត៌មាន។ សិទ្ធិទាំងនេះ មានសារៈសំខាន់ណាស់ ជាពិសេសសម្រាប់ដំណើរការប្រជាធិបតេយ្យ ទាំងនៅក្នុងអំឡុងពេលនៃការបោះឆ្នោត ទាំងនៅចន្លោះពេលនៃការបោះឆ្នោត ដូចដែលបានគូសបញ្ជាក់ដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងខាងសមាគម (អ្នករាយការណ៍ពិសេស SRFOAA)។ លោកបានបញ្ជាក់ថា "សិទ្ធិទាំងនេះ គឺជាសមាសភាគដ៏សំខាន់ជាសារវ័ន្តនៃលទ្ធិប្រជាធិបតេយ្យ ដោយសារថា សិទ្ធិទាំងនេះ ផ្តល់សិទ្ធិអំណាចដល់ស្ត្រី បុរស និងយុវជនក្នុងការ"បញ្ចេញមតិនយោបាយរបស់ខ្លួន ចូលរួមក្នុងការខិតខំប្រឹងប្រែងខាងអក្សរសាស្ត្រ និងសិល្បៈ និងក្នុងសកម្មភាពផ្សេងទៀតខាងវប្បធម៌ សង្គម និងសេដ្ឋកិច្ច ចូលរួមក្នុងការគោរពប្រតិបត្តិសាសនា ឬជំនឿផ្សេងៗ បង្កើត និងចូលរួមក្នុងការងារសហជីព និងសាជីវកម្ម និងបោះឆ្នោតជ្រើសរើសមេដឹកនាំដើម្បីតំណាងឲ្យផលប្រយោជន៍របស់ខ្លួន និងដាក់ឲ្យពួកគេទទួលខុសត្រូវ។[1] បើតាមប្រសាសន៍របស់អ្នករាយការណ៍ពិសេស SRFOAA "សមាគម" រាប់ទាំងគណបក្សនយោបាយផងដែរ ត្រូវបានគេស្គាល់ជាទូទៅថាជាក្បាលម៉ាស៊ីនដ៏សំខាន់ ហើយដែលតាមរយៈនេះ បុគ្គលទាំងឡាយ អាចចូលរួមដឹកនាំកិច្ចការផ្សេងៗប្រកបដោយសន្តិវិធី តាមរយៈតំណាងដែលខ្លួនបានជ្រើសរើស។[2] ទស្សនៈរបស់អ្នករាយការណ៍ពិសេស SRFOAA ពង្រឹងបន្ថែមលើទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (គណៈកម្មាធិការសិទ្ធិមនុស្ស) ជាស្ថាប័នជំនាញដែលតាមឃ្លាំមើលការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលតាមទស្សនៈទាំងនោះ ប្រជាពលរដ្ឋមានសិទ្ធិ "ចូលរួមដឹកនាំកិច្ចការសាធារណៈ ដោយប្រើប្រាស់ឥទ្ធិពលតាមរយៈកិច្ចសន្ទនា និងជជែកដេញដោលជាសាធារណៈជាមួយតំណាងរបស់ខ្លួន ឬតាមរយៈសមត្ថភាពរបស់ខ្លួនក្នុងការរៀបចំខ្លួនឯងផ្ទាល់។ ការចូលរួមនេះត្រូវបានគាំទ្រ តាមរយៈការធានាសេរីភាពក្នុងការបញ្ចេញ

---

[1] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប លេខ 15/21, ដូចបានបញ្ជាក់បញ្ជាក់ដោយអ្នករាយការណ៍ពិសេស នៅក្នុងរបាយការណ៍លេខ A/68/299 (ឆ្នាំ2013), កថាខណ្ឌ 5។

[2] របាយការណ៍លេខ A/68/299, កថាខណ្ឌ ៩។

មតិ ការជួបប្រជុំ និងខាងសមាគម។"[3] គណៈកម្មាធិការសិទ្ធិមនុស្ស បន្តពិចារណាថា "សេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំ និងខាងសមាគម គឺជាលក្ខខណ្ឌដ៏សំខាន់ជាសារវ័ន្តសម្រាប់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិបោះឆ្នោត ហើយដែលត្រូវតែបានការពារយ៉ាងពេញលេញ។"[4]

សុចរិតភាពនៃការបោះឆ្នោតនៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស មិនអាចនឹងត្រូវបានធានាឡើយ ប្រសិនជាគណបក្សនយោបាយទាំងឡាយមិនអាចប្រើប្រាស់សេរីភាពបញ្ចេញមតិយោបល់ រាប់ទាំងសិទ្ធិក្នុងការស្វែងរក ការទទួលព័ត៌មាន និងការចែករំលែកព័ត៌មាន។ គណបក្សនយោបាយទាំងឡាយ គួរដើរតួនាទីជាកាតាលីករសម្រាប់កិច្ចសន្ទនា និងការជជែកដេញដោលក្នុងសង្គមប្រជាធិបតេយ្យ។[5] នេះគួរតែអនុញ្ញាតឲ្យមនុស្សគ្រប់រូបបង្កើតទស្សនៈដោយឯករាជ្យ ដោយគ្មានអំពើហិង្សា ការបង្ខិតបង្ខំ ការបញ្ចុះបញ្ចូល ឬការជ្រៀតជ្រែក ទោះជាតាមរូបភាពណាក៏ដោយ។[6] ដូច្នេះ វាគឺជាលក្ខខណ្ឌចាំបាច់ដែលសេរីភាពក្នុងការបញ្ចេញមតិ ត្រូវរួមបញ្ចូលនូវការការពារមិនឲ្យមានការរើសអើងប្រឆាំងនឹងការបង្កើតគណបក្សទាំងឡាយណាដែលមានគំនិត ឬទស្សនៈផ្សេងគ្នា។ យុត្តិសាស្រ្តរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប បានពង្រឹងកាតព្វកិច្ចរបស់រដ្ឋទាំងឡាយនៅក្នុងបញ្ហានេះ ចំពោះការការពារ "មិនត្រឹមតែចំពោះ "ព័ត៌មាន" ឬ "គំនិត" ដែលទទួលបានគាំទ្រ ឬចាត់ទុកថាមិនជំទាស់ ឬថាជាបញ្ហាមិនសំខាន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះព័ត៌មាន គំនិត ឬទស្សនៈទាំងឡាយដែលជំទាស់ មិនគាំទ្រ ឬរំខានផងដែរ។[7]"

ការទទួលខុសត្រូវ គឺជាបន្ទុករបស់រដ្ឋ នេះបើយោងតាមមាត្រា៤.១ នៃសេចក្តីប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌របស់សហភាពអន្តរសភា ដែលថា រដ្ឋត្រូវ"ផ្តល់ឲ្យមានការបង្កើត និងការប្រព្រឹត្តទៅដោយសេរីនៃគណបក្សនយោបាយ... និងបង្កើតលក្ខខណ្ឌសម្រាប់ការប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្ត ដោយឈរលើគោល

---

[3] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លើមាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR), ឆ្នាំ1996, កថាខណ្ឌ 8។

[4] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ២៥, CCPR/C/21/Rev.1/Add.7, កថាខណ្ឌ 12។

[5] របាយការណ៍លេខ A/38/299, para. 38។

[6] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ 34, para. 19។

[7] សំណុំរឿងក្តី Refah Partisi (The Welfare Party) និង Others v. Turkey, តុលាការសិទ្ធិមនុស្សសិទ្ធិមនុស្សអឺរ៉ុប សំណុំរឿងលេខ 41340/98, 41342/98 និង 41344/98, 13 កុម្ភៈ 2003។

ការណ៍សមធម៌។"[8]

សេចក្តីវិភាគនេះ ទាញយកចំណុចសំខាន់ៗពីរដ្ឋធម្មនុញ្ញកម្ពុជា[9] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR) ដែលកំណត់ពីសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងខាងសមាគម។ សម្រង់ពាក់ព័ន្ធនៃលិខិតុបករណ៍មានដូចខាងក្រោមទាំងនេះ៖

- មាត្រា ១ កថាខណ្ឌ ១ នៃរដ្ឋធម្មនុញ្ញ៖

  "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។"

- មាត្រា ៤១ កថាខណ្ឌ ១ នៃរដ្ឋធម្មនុញ្ញ៖

  " ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរី

  ភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើប្រាស់សិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិបានឡើយ។"

- មាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ៖

  ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

  ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមកការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។

---

[8] សេចក្តីប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌របស់សហភាពអន្តរសភា អនុម័តនៅថ្ងៃទី 26 ខែមិនា ឆ្នាំ1994, សូមមើលគេហទំព័រ: http://www.ipu.org/Cnl-e/154-free.htm

[9] ការប្រែមិនផ្លូវការ, សំណៅដែលគ្រប់គ្រងដោយក្រុមប្រឹក្សាធម្មនុញ្ញ ខែតុលា ឆ្នាំ 2015. សូមមើលគេហទំព័រ: http://www.ccc.gov.kh/english/basic_text/Constitution%20of%20the%20Kingdom%20of%20Cambodia.pdf.

- មាត្រា ៥១ នៃរដ្ឋធម្មនុញ្ញ៖

" ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយ ប្រជាធិបតេយ្យ សេរីពហុបក្ស។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិខ្លួន។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។"

- មាត្រា ១៦០ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ៖

"ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមផ្លូវច្បាប់របស់បុគ្គល និងដែលសមស្របនឹងផលប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណា ដែលផ្ទុយនឹងស្មារតី នៃរដ្ឋធម្មនុញ្ញនេះ។"

- មាត្រា ២៥ នៃ ICCPR៖

ដោយគ្មានការបែងចែក ដូចដែលបានចែងក្នុងមាត្រា២ និងដោយគ្មានការរិតត្បិត ដែលមិនសមហេតុផល ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងមានឱកាស៖

(ក) រួមចំណែកក្នុងដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងដែលខ្លួនជ្រើសរើសដោយសេរី។

(ខ) បោះឆ្នោត និងឈរឈ្មោះបោះឆ្នោត នៅក្នុងការបោះឆ្នោតពិតប្រាកដតាមកាលកំណត់ទៀងទាត់ ជាសកល ស្មើភាព និងដោយសម្ងាត់ ដែលធានាការបញ្ចេញមតិដោយសេរីពីឆន្ទៈអ្នកបោះឆ្នោត។

(គ) ចូលបម្រើមុខងារសាធារណៈក្នុងប្រទេសរបស់ខ្លួន ក្នុងលក្ខខណ្ឌទូទៅដោយសមភាព។

- មាត្រា ១៩ នៃ ICCPR៖

"១. ជនគ្រប់រូបមាន សិទ្ធិប្រកាន់យកមតិយោបល់ ដោយគ្មានការជ្រៀតជ្រែក។

២. ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។

៣. ការប្រើប្រាស់សិទ្ធិដែលចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ តម្រូវឲ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតមួយចំនួន ដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី៖

(ក) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ។

(ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។

- មាត្រា២២ នៃ ICCPR៖

១. ជនគ្រប់រូប មានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

២. ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។ មាត្រានេះ មិនរារាំងដល់ការរិតត្បិតខាងផ្លូវច្បាប់ លើសមាជិកយោធា និងនគរបាល ក្នុងការប្រើប្រាស់សិទ្ធិនេះទេ។

សិទ្ធិទាំងនេះ ជារបស់មនុស្សគ្រប់រូបដោយមិនគិតពីអាយុ សញ្ជាតិ និន្នាការនយោបាយ ឬស្ថានភាពដទៃទៀតឡើយ ហើយសិទ្ធិទាំងនេះ ត្រូវបានអះអាងជាថ្មីម្តងហើយម្តងទៀតដោយស្ថាប័នអន្តរជាតិនានាដល់បណ្តាប្រទេសទាំងអស់ រាប់ទាំងប្រទេសកម្ពុជាផងដែរ។ នៅក្នុងសេចក្តីសង្កេតចុងក្រោយបំផុតរបស់ខ្លួនស្តីពីប្រទេសកម្ពុជា គណៈកម្មាធិការសិទ្ធិមនុស្ស បានចេញអនុសាសន៍ជាច្រើនជាពិសេសអំពីសិទ្ធិទាំងនេះ រាប់ទាំងដើម្បី "ធានាថាមនុស្សគ្រប់រូបអាចប្រើប្រាស់ដោយសេរីនូវសិទ្ធិសេរីភាពរបស់ខ្លួនក្នុងការបញ្ចេញមតិ និងការបង្កើតសមាគម... ក្នុងការធ្វើដូច្នេះ រដ្ឋភាគីគួរតែ៖ (ឃ) ពិនិត្យឡើងវិញនូវច្បាប់បច្ចុប្បន្ន និងច្បាប់ដែលរង់ចាំការអនុម័តរបស់ខ្លួន... ដើម្បីជៀសវាងការប្រើប្រាស់ពាក្យពេចន៍មិនច្បាស់លាស់ និងការរឹតត្បិតទូលំទូលាយពេក ដើម្បីធានាថាការរឹតត្បិតណាមួយលើការ

ប្រើប្រាស់សេរីភាពក្នុងការបញ្ចេញមតិ និងខាងសមាគម ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដ៏តឹងរឹងនៃមាត្រា១៩(៣) និងមាត្រា២២ នៃកតិកាសញ្ញានេះ។"[10]

ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបាន "ក្រើនរំលឹកដល់រដ្ឋទាំងឡាយអំពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការគោរព និងការការពារយ៉ាងពេញលេញនូវសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការ... ប្រាស្រ័យទាក់ទងគ្នាដោយសេរី ទាំងតាមអនឡាញ និងអូហ្វឡាញ រាប់ទាំងក្នុងបរិបទនៃការបោះឆ្នោត និងរាប់ទាំងអ្នកដែលគាំទ្រជនភាគតិច ឬទស្សនៈ ឬជំនឿផ្ទុយ អ្នកការពារសិទ្ធិមនុស្ស សកម្មជនសហជីព និងអ្នកដទៃផ្សេងទៀត រាប់ទាំងទេសន្តរប្រវេសន៍ ដែលស្វែងរកការអនុវត្ត ឬការលើកកម្ពស់សិទ្ធិទាំងនេះ និងដើម្បីចាត់វាល់វិធានការណ៍ចាំបាច់ ដើម្បីធានាថាការរឹតត្បិតណាមួយលើការប្រើប្រាស់សិទ្ធិ... សេរីភាពខាងសមាគម ត្រូវអនុលោមតាមកាតព្វកិច្ចរបស់ខ្លួន ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។"[11]

បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទទួលស្គាល់ថា ការកម្រិតកំណត់លើសិទ្ធិទាំងនេះ អាចជាការចាំបាច់ស្ថិតក្រោមកាលៈទេសៈជាក់លាក់មួយចំនួន ដូច្នេះហើយលក្ខខណ្ឌសម្រាប់ការកម្រិតកំណត់ដែលអនុញ្ញាត ត្រូវបានបញ្ចូលទៅក្នុងស្តង់ដាររបស់វាផ្ទាល់ ដូចបានបង្ហាញស្រាប់នៅក្នុងកថាខណ្ឌទី២ នៃមាត្រា១៩ និងមាត្រា២២។ បញ្ហានេះ ត្រូវបានពិនិត្យនៅក្នុងផ្នែកខាងក្រោមដែលមានចំណងជើង "ការរឹតត្បិតដែលអនុញ្ញាតលើសិទ្ធិមនុស្ស។"

គណៈកម្មការអឺរ៉ុបសម្រាប់ប្រជាធិបតេយ្យតាមរយៈច្បាប់ ("គណៈកម្មការទីក្រុងវ៉ឺនីស"នៃក្រុមប្រឹក្សាអឺរ៉ុប) នៅក្នុងគោលការណ៍ណែនាំរបស់ខ្លួនស្តីពីបទប្បញ្ញត្តិគណបក្សនយោបាយ បានពន្យល់ដូចខាងក្រោមនេះ៖ ច្បាប់ស្តីពីគណបក្សនយោបាយ មិនគួរជ្រៀតជ្រែកដល់សេរីភាពខាងសមាគម ហើយសមាមាត្រភាព គួរតែត្រូវបានថ្លឹងថ្លែងដោយប្រុងប្រយ័ត្ន និងវិធានហាមប្រាមទាំងឡាយ គួរតែបានអនុវត្តនៅក្នុងន័យចង្អៀត។ ការប្តេជ្ញាចិត្តនៃតួនាទីដ៏ត្រឹមត្រូវរបស់រដ្ឋក្នុងការប្បញ្ញត្តិគណបក្សនយោបាយតម្រូវឲ្យមានការពិគ្រោះយោបល់ជាមួយបុគ្គល និងក្រុមទាំងឡាយដែលរងផលប៉ះពាល់ដោយការប្បញ្ញត្តិនេះ ដែលជាផ្នែកមួយនៃដំណើរការធ្វើសេចក្តីព្រាងច្បាប់។ ការកម្រិតកំណត់ទៅលើសិទ្ធិរបស់បុគ្គលខាងសមាគម និងការបញ្ចេញមតិដោយសេរី មិនគួរជាផលដែលកើតចេញពីសកម្មភាពនយោបាយប្រកាន់បក្សពួកឡើយ ផ្ទុយទៅវិញគឺត្រូវឈរលើគោលបំណងធម្មានុរូបមួយ ដែលចាំបាច់

---

[10] សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លើរបាយការណ៍តាមកាលកំណត់លើកទី២របស់កម្ពុជា, CCPR/C/KHM/CO/2, ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៥។

[11] សេចក្តីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លេខ A/HRC/RES/24/5, para. 2.

ក្នុងសង្គមប្រជាធិបតេយ្យ។[12]

បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ តម្រូវឲ្យមានលក្ខណៈច្បាស់លាស់នៅក្នុងច្បាប់នេះ។ ក្នុងន័យនេះ មានបទប្បញ្ញត្តិជាច្រើននៅក្នុងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មមានលក្ខណៈស្រពិចស្រពិល ឬមិនច្បាស់លាស់ដែលអាចនាំឲ្យមាន ឧទាហរណ៍ ការព្យួរ ឬការរំលាយគណបក្សនយោបាយមួយ ឬការកម្រិតកំណត់ដោយបំពានលើសិទ្ធិនយោបាយ ឬសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងខាងសមាគម ដូចដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។ ប្រជាពលរដ្ឋ មិនរំពឹងថានឹងគោរពអនុវត្តច្បាប់មួយដែលពួកគេមិនយល់នោះឡើយ។ "... ការរឹតត្បិតត្រូវតែច្បាស់លាស់ ងាយស្រួលយល់ ហើយត្រូវអនុវត្តដោយស្មើភាពគ្នា ដើម្បីធានាថាបុគ្គល និងបក្សទាំងអស់ អាចយល់ពីផលវិបាកកើតចេញពីការរំលោភបំពានលើការរឹតត្បិតទាំងនោះ។ ការរឹតត្បិត ត្រូវតែជាការចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ និងការការពារពេញលេញនូវសិទ្ធិ ត្រូវបានសន្មត់ក្នុងគ្រប់ករណីទាំងអស់ដែលខ្វះការរឹតត្បិតជាក់លាក់។ ដើម្បីធានាថា ការរឹតត្បិត មិនត្រូវបានអនុវត្តដោយបំពានច្បាប់ បទប្បញ្ញត្តិត្រូវតែបានធ្វើឡើងដោយប្រុងប្រយ័ត្ន ទាំងមិនលម្អិតពេក និងទាំងមិនស្រិចស្រពិលពេក។"[13] ក្នុងន័យនេះ មានពាក្យពេចន៍ជាច្រើនដែលមិនច្បាស់លាស់នៅក្នុងច្បាប់នេះ ដូចជា "ឯកភាពជាតិ" "សន្តិសុខនៃរដ្ឋ" និង "កំហុសធ្ងន់ធ្ងរ" ដែលតម្រូវឲ្យមានការពន្យល់បំភ្លឺឲ្យស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

កង្វល់ផ្សេងទៀត គឺកើតចេញពីកង្វះកិច្ចធានាការពារខាងនីតិវិធីត្រឹមត្រូវ។ ច្បាប់ស្តីពីគណបក្សនយោបាយដែលបានប្រគល់ភារកិច្ចនេះឲ្យទៅក្រសួងមហាផ្ទៃជាអ្នកគ្រប់គ្រងលើគណបក្សនយោបាយ គឺផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ ដែលតម្រូវឲ្យស្ថាប័នមួយស្វយ័តឯករាជ្យពីអង្គនីតិប្រតិបត្តិ ដើម្បីធានាការប្រព្រឹត្តទៅដោយស្មើភាពនូវការប្រកួតប្រជែងខាងនយោបាយ។ ក្រសួងមហាផ្ទៃ ត្រូវបានប្រគល់អំណាចដ៏ធំធេង ក្នុងការចាត់វិធានការណ៍ឈានទៅរកការរំលាយ*តាមព្រឹត្តន័យ* នូវគណបក្សនយោបាយ។ លទ្ធភាពប្តឹងតវ៉ា ត្រូវបានអនុញ្ញាតសម្រាប់តែបណ្តឹងតវ៉ាដោយផ្ទាល់ទៅតុលាការកំពូលប៉ុណ្ណោះ ជំនួសឲ្យដំណើរការក្តីតាមធម្មតា ដែលមានបីដំណាក់កាល តាមរយៈសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ដែលជាអ្នកសម្រេចសេចក្តីចុងក្រោយបិទផ្លូវតវ៉ា។ កង្វល់ខ្លាំងបន្ថែមទៀតនោះគឺថា ក្នុងការចែងបរិយាយអំពីអ្នកដែល*មិន*អាចដឹកនាំគណបក្សនយោបាយ ច្បាប់នេះ មិនបានរួម

[12] គោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិគណបក្សនយោបាយ ដោយ OSCE/ODIHR និងគណៈកម្មការទីក្រុងវីនីស, អនុម័តដោយគណៈកម្មការទីក្រុងវីនីស នៅក្នុងកិច្ចប្រជុំពេញអង្គរបស់ខ្លួនលើកទី ៨៤, (ទីក្រុងVenice, ថ្ងៃទី15-16 តុលា 2010) , pp. 7, 9-10។ អាចរកបាននៅ http://www.venice.coe.int/webforms/documents/default.aspx?pdffile=CDL-AD(2010)024-e.

[13] គោលការណ៍ណែនាំរបស់OSCE កថាខណ្ឌ ៤៩។

បញ្ចូលទៅក្នុងបញ្ជីនេះនូវសមាជិករដ្ឋាភិបាល មន្ត្រីយោធាជាន់ខ្ពស់ និងមន្ត្រីរាជការផ្សេងទៀត រាប់ទាំងសមាជិកតុលាការផងទេ។ ក្នុងបញ្ហានយោបាយជាតួយ៉ាងនេះ ដូចជាការចុះឈ្មោះ និងការរំលាយគណបក្សប្រឆាំងជាដើម អង្គហេតុដែលគណបក្សទាំងនោះត្រូវបានអនុញ្ញាតស្របច្បាប់ជាសមាជិកសកម្ម ឬមេដឹកនាំគណបក្សមួយ ផ្តល់ហេតុផលជាច្រើននូវការមន្ទិលសង្ស័យពីភាពមិនលំអៀង និងភាពត្រឹមត្រូវនៃការដឹកនាំរបស់ពួកគេក្នុងបញ្ហានេះ ជាពិសេស នៅពេលមិនមានបញ្ញត្តិដែលចែងធានាការពារក្នុងករណីមានទំនាស់ផលប្រយោជន៍។

នៅក្នុងទិដ្ឋភាពផ្សេងទៀត ច្បាប់ស្តីពីវិសោធនកម្មនេះ ឆ្លុះបញ្ចាំងពីការអនុវត្តន៍ទូទៅជាអន្តរជាតិ និងដែលអាចទទួលយកបាន ដូចជាការប្រគល់ភារកិច្ចឲ្យតែតុលាការមានសមត្ថកិច្ចក្នុងការរំលាយគណបក្សនយោបាយមួយជាផ្លូវការ ស្ថិតក្រោមបញ្ញត្តិរក្សាទុកខាងលើ។ ឧទាហរណ៍មួយទៀត គឺបទប្បញ្ញត្តិដែលនិយាយពីការផ្តល់មូលនិធិពីប្រភពបរទេស។ ទន្ទឹមនឹងនេះ ការបញ្ជាក់ឲ្យកាន់តែច្បាស់លាស់ថែមទៀតនោះ តាមរយៈនិយមន័យច្បាស់លាស់ជាងនេះនៃពាក្យ "បរទេស" និង "ជនបរទេស" គឺជាការចាំបាច់ ដើម្បីធានាថាប្រភពផ្តល់មូលនិធិស្របច្បាប់ នឹងមិនត្រូវបានហាមប្រាមឡើយ ដូចជាការរួមវិភាគទានពីអណិកជនខ្មែរ ឬពលករទេសន្តរប្រវេសន៍នៅក្រៅប្រទេស ហើយជាមួយនឹងការពិនិត្យឡើងវិញលើការរិតត្បិតលើមូលនិធិបរទេស នឹងអាចជួយបង្ការការដកហូតវេទិការគណបក្សណាមួយ និងការសម្រេចចិត្តដែលកើតចេញពីឆន្ទៈរបស់សមាជិករបស់ខ្លួន។

សិទ្ធិក្នុងការចូលរួមតម្រូវថា នៅមុនពេលសេចក្តីព្រាងច្បាប់មួយត្រូវបានអនុម័តឲ្យទៅជាច្បាប់ ឬសេចក្តីស្នើវិសោធនកម្មត្រូវបានអនុម័ត ខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើវិសោធនកម្ម ត្រូវតែបានធ្វើឡើងយ៉ាងណាឲ្យអាចស្វែងរកបាន មិនចំពោះតែអ្នកដែលពាក់ព័ន្ធដោយផ្ទាល់នោះទេ ប៉ុន្តែចំពោះសាធារណជនទូទៅផងដែរ។ ក្នុងន័យនេះ គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់ជាអនុសាសន៍ថា កម្ពុជា "គួរតែធានាឲ្យមានតម្លាភាពក្នុងដំណើរការធ្វើច្បាប់/តាក់តែងច្បាប់ និងពិចារណាដាក់រាល់សេចក្តីព្រាង/ស្នើរច្បាប់ទាំងអស់ឲ្យសាធារណៈជនអាចរកបាន ដើម្បីជួយសម្រួលដល់ការសន្ទនា និងការជជែកពិភាក្សាជាសាធារណៈ ដោយប្រជាពលរដ្ឋជាមួយនឹងតំណាងរបស់ពួកគេ ។"[14]

ការិយាល័យOHCHR មានការសោកស្តាយថា មិនមានដំណើរការពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីស្នើវិសោធនកម្មដែលគួរតែបានអនុញ្ញាតឲ្យមានការពិនិត្យឲ្យស៊ីជម្រៅឡើងវិញ។ ដែលនេះ អាចនឹងតម្រូវឲ្យមានការទុកពេលវេលាគ្រប់គ្រាន់ ដើម្បីអាចឲ្យសាធារណៈជនដែលមានចំណាប់

---

[14] សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លើរបាយការណ៍តាមកាលកំណត់លើកទី២របស់កម្ពុជា, CCPR/CO/KHM/2 (2015), para. 25.

អារម្មណ៍ធ្វើការពិនិត្យឡើងវិញយ៉ាងហ្មត់ចត់ និងដើម្បីជជែកពិភាក្សា។ ជាការពិតណាស់ ការប្រមូលរាល់មតិយោបល់តាមរយៈការពិគ្រោះយោបល់ពិតប្រាកដ ប្រកបអត្ថន័យ មុនពេលអនុម័ត គួរតែអនុវត្តជាប្រចាំចំពោះគ្រប់សេចក្ដីព្រាង/ស្នើរច្បាប់ទាំងអស់។

ការិយាល័យOHCHR សម្តែងនូវក្តីសង្ឃឹមថា ការពិគ្រោះយោបល់បែបនេះ នឹងត្រូវបានរៀបចំធ្វើឡើង សូម្បីតែបន្ទាប់ពីការអនុម័តលើវិសោធនកម្មរួចហើយក្តី ដែលអាចរួមចំណែកដល់ការពិនិត្យឡើងវិញលើច្បាប់បច្ចុប្បន្ន ដែលអាចទទួលយកបានដោយប្រជាពលរដ្ឋកម្ពុជា ហើយស្របតាមច្បាប់សិទ្ធិមនុស្ស។ ការិយាល័យOHCHR សូមផ្តល់នូវសេចក្តីសង្កេត និងអនុសាសន៍របស់ខ្លួនសម្រាប់ការពិនិត្យឡើងវិញជាយថាហេតុណាមួយ ដោយសង្ឃឹមថានឹងរួមចំណែកដល់ការអនុម័តច្បាប់ដ៏រឹងមាំមួយស្តីពីគណបក្សនយោបាយ ដែលគោរពពេញលេញចំពោះសិទ្ធិមនុស្ស។

## II. ការរឹតត្បិតដែលអនុញ្ញាតលើសិទ្ធិមនុស្ស

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR) ប្រមើលឃើញថា ការរឹតត្បិត អាចនឹងត្រូវបានយកមកដាក់ជំនួសទៅលើការប្រើប្រាស់សិទ្ធិសេរីភាពខាងសមាគមស្ថិតក្រោមកាលៈទេសៈជាក់លាក់មួយចំនួន ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា១៩ និងមាត្រា២២។ តាមរបៀបនេះ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ត្រូវបានបរិយាយដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវចំពោះការថ្លឹងថ្លែងដ៏ប្រុងប្រយ័ត្នដែលចាំបាច់សម្រាប់រដ្ឋទាំងឡាយ ក្នុងការការពារ ការគោរព និងការបំពេញសិទ្ធិមនុស្ស ដោយមិនធ្វើឲ្យអន្តរាយដល់គោលបំណងស្របច្បាប់នៃការរក្សាសន្តិភាពក្នុងលិទ្ធិប្រជាធិបតេយ្យ។

ការរឹតត្បិតមួយចំនួន តាមធម្មតាមិនត្រូវបានបានអនុញ្ញាតឡើយ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិគូសបញ្ជាក់ពីសិទ្ធិមួយចំនួនដែលមិនអាចបដិប្បញ្ញត្តិបានឡើយ ទោះជាស្ថិតក្រោមកាលៈទេសៈណាក៏ដោយ។[15] មាត្រា១៥២ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញចែងថា "ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត" ដោយរាប់ទាំងសិទ្ធិមនុស្សដែលមានចែងក្នុងជំពូកទី៣ នៃរដ្ឋធម្មនុញ្ញផងដែរ។

ដូចមានចែងក្នុងមាត្រា១៩ និងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ការរឹតត្បិត អាចអនុញ្ញាតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។ ការរឹតត្បិតស្រដៀងគ្នានេះ ត្រូវបានកំណត់ផងដែរក្នុងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញ។ ការរឹតត្បិត ណាមួយត្រូវបានផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួនបី ដើម្បីអាចចាត់ទុកថាអនុញ្ញាតបាន ដូចខាងក្រោម ៖

- *"ភាពចាំបាច់"* នៃការរឹតត្បិតដែលបានស្នើឡើងសម្រាប់ការធ្វើឲ្យសម្រេចគោលដៅជាក់លាក់មួយ ត្រូវតែបានបង្ហាញដោយមិនលំអៀង។

---

[15] រាប់ទាំងសិទ្ធិរស់រានមានជីវិត, ការហាមឃាត់ការធ្វើទារុណកម្ម, ការប្រព្រឹត្តដោយឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក, ការហាមឃាត់ការពិសោធន៍ផ្នែកវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រ ដោយមិនមានការយល់ព្រម, ការហាមឃាត់ទាសភាព, ការជួញដូរទាសភាព និងសេវិកភាព, ការហាមឃាត់ការផ្តន្ទាទោសដាក់ពន្ធនាគារដោយមូលហេតុអលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចនៃកិច្ចសន្យា, គោលការណ៍នីត្យានុកូលនៃច្បាប់ព្រហ្មទណ្ឌ, ការទទួលស្គាល់គ្រប់ទីកន្លែងនូវភាពជាមនុស្សចំពោះមុខច្បាប់, សេរីភាពខាងគំនិត មនសិការ និងសាសនា។

- ការរឹតត្បិតដែលបានស្នើឡើង ត្រូវតែដាក់ឲ្យមានការធ្វើតេស្តយ៉ាងតឹងរឹងអំពី*សមាមាត្រភាព* ដើម្បីធានាថា វាសមាមាត្រត្រឹមត្រូវមិនលំអៀងទៅនឹងការគំរាមកំហែងពិតប្រាកដ។ នៅពេលដែលវិធានការណ៍ជាជម្រើសផ្សេងៗអាចមាន គេគួរតែជ្រើសរើសយកការរឹតត្បិតមួយដែលតិចតួចបំផុតក្នុងចំណោមការរឹតត្បិតទាំងនោះ ហើយអនុវត្តសម្រាប់តែមួយរយៈពេលដែលចាំបាច់ប៉ុណ្ណោះ ដើម្បីសម្រេចគោលដៅនោះ។
- ការរឹតត្បិត មិនអាចត្រូវបានអនុវត្តឡើយ លើកលែងតែ*ត្រូវបានកំណត់ ដោយច្បាប់។*

ការរួមបញ្ចូលគ្នានៃសមាសធាតុទាំងបីនេះ គឺពេលខ្លះត្រូវបានយោងទៅលើសរុបភាពរបស់វាជាលក្ខណៈវិនិច្ឆ័យសម្រាប់ "ភាពសមហេតុផល" នៃការរឹតត្បិតដែលបានស្នើឡើង។[16] ប្រទេសទាំងអស់មានកង្វល់អំពីសណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិ ហើយអាចមានយុត្តិកម្មសមហេតុផលសម្រាប់កង្វល់បែបនេះ។ ទោះជាយ៉ាងណាក៏ដោយ ប្រការនោះវាមិនគ្រប់គ្រាន់ទេ សម្រាប់ការដាក់កំហិតសេរីភាពខាងសមាគម ដូច្នេះការដាក់កំហិតទាំងនេះ មិនអាចធ្វើដោយគ្មានកំណត់ព្រំដែនច្បាស់លាស់បានឡើយ។ តាមរយៈយុទ្ធសាស្ត្ររបស់ខ្លួន ក្រុមប្រឹក្សាសិទ្ធិមនុស្សបានពន្យល់ថា រដ្ឋភាគី "ត្រូវតែបង្ហាញបន្ថែមទៀតថា ការហាមប្រាមចំពោះសមាគម និងការចោទប្រកាន់ខាងព្រហ្មទណ្ឌទៅលើបុគ្គល ចំពោះសមាជិកភាពក្នុងអង្គការបែបនេះ គឺតាមពិតជាការចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ពិតប្រាកដ ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់ប្រជាធិបតេយ្យ មិនមែនជាគ្រោះថ្នាក់សម្មតិកម្មឡើយ ហើយវិធានការទាំងឡាយដែលមានលក្ខណៈរំលោភបំពានទោះតិចតួចក្តី នឹងក្លាយជាវិធានការមិនគ្រប់គ្រាន់ ដើម្បីសម្រេចគោលដៅនេះ។"[17]

ចំណុចនេះ ត្រូវបានបន្ទរនៅក្នុងមាត្រា៣.៧ នៃសេចក្តីប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌របស់សហភាពអន្តរសភាដែលកំណត់ថា ការរឹតត្បិតគួរតែមានចរិតអញ្ញត្រកម្ម ដែលស្របតាមច្បាប់ និងលក្ខណៈចាំបាច់សមហេតុផលក្នុងសង្គមប្រជាធិបតេយ្យ និងស្របទៅនឹងកាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់អន្តរជាតិ។ មាត្រានេះ ហាមឃាត់ការអនុវត្តដោយមានការរើសអើងនៃការរឹតត្បិតដែលច្បាប់អនុញ្ញាតលើបេក្ខភាព ការបង្កើត និងការធ្វើសកម្មភាពរបស់គណបក្សនយោបាយ និងសិទ្ធិធ្វើយុទ្ធនាការ ដោយឈរលើបញ្ហាពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា

[16] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ 25, para. 4: "លក្ខខណ្ឌទាំងឡាយដែលអនុវត្តចំពោះការប្រើប្រាស់សិទ្ធិទាំងឡាយដែលការពារដោយមាត្រា ២៥ គួរតែត្រូវផ្អែកទៅលើលក្ខណៈវិនិច្ឆ័យនៃគោលដៅ និងសមហេតុផល" ។ សូមមើលផងដែរនូវបណ្តឹងលេខ 932/2000, សំណុំរឿងក្តីGillot et al. v. France, ទស្សនៈ ត្រូវបានអនុម័តនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០២។

[17] សូមមើលបណ្តឹងលេខNo. 1119/2002, សំណុំរឿងក្តី Lee v. the Republic of Korea, ទស្សនៈ ត្រូវបានអនុម័តនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥។

គំនិតនយោបាយ ឬគំនិតផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃផ្សេងទៀត។

យុត្តិកម្មទូទៅមួយដែលបានធ្វើឡើងសម្រាប់ការរឹតត្បិតគឺ ទាក់ទងនឹងសន្តិសុខជាតិ។ ក្នុងន័យនេះ គោលការណ៍ស៊ីរ៉ាគូសា (Siracusa Principles) ស្តីពីបទប្បញ្ញត្តិកម្រិតកំណត់ និងដែលអាចព្យួរបាន នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ [18] ពន្យល់ប្រាប់អំពីពេលណាអនុញ្ញាត ហើយពេលណាមិនអនុញ្ញាត ដូចខាងក្រោម៖

> ៣០. សន្តិសុខជាតិ អាចនឹងត្រូវបានប្រើដើម្បីធ្វើយុត្តិកម្មនូវវិធានការណ៍ទាំងឡាយដែលកម្រិតកំណត់សិទ្ធិជាក់លាក់មួយចំនួនតែប៉ុណ្ណោះ នៅពេលដែលវិធានការណ៍ទាំងនោះត្រូវបានចាត់ដើម្បីការពារអត្ថិភាពជាតិ ឬបូរណភាពទឹកដីរបស់ខ្លួន ឬឯករាជ្យភាពនយោបាយប្រឆាំងនឹងកម្លាំង ឬការគំរាមកំហែងប្រើប្រាស់កម្លាំង។
>
> ៣១. សន្តិសុខជាតិ មិនអាចត្រូវបានគេយកធ្វើជាហេតុផលសម្រាប់ការដាក់កម្រិតកំណត់ដើម្បីគ្រាន់តែបង្ការ ការគំរាមកំហែងធម្មតា ឬដោយប្រយោលទៅនឹងច្បាប់ និងបទបញ្ជាមួយណាឡើយ។
>
> ៣២. សន្តិសុខជាតិ មិនអាចត្រូវបានប្រើជាលេសសម្រាប់ការដាក់កម្រិតកំណត់មិនច្បាស់លាស់ ឬដោយបំពានឡើយ ហើយវាអាចត្រូវបានប្រើប្រាស់ នៅពេលដែលមានការធានាការពារគ្រប់គ្រាន់ និងការដោះស្រាយប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងការរំលោភបំពាន។

បើយោងតាមការស្រាវជ្រាវរបស់សហភាពអន្តរសភា ស្តីពីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ "យុត្តិសាស្ត្រទូទៅស្តីពីការបដិសេធ ឬការដាក់កម្រិតសិទ្ធិនយោបាយ បង្ហាញថា វិធានការណ៍នេះនឹងរំលោភលើសិទ្ធិបុគ្គល ប្រសិនជាមិនសមហេតុផល ដោយបំពាន ឬមិនសមាមាត្រ ។"[19]

---

[18] គណៈកម្មការសិទ្ធិមនុស្ស អ.ស.ប, គោលការណ៍ស៊ីរ៉ាគូសា ស្តីពីបទប្បញ្ញត្តិកម្រិតកំណត់ និងដែលអាចព្យួរ បាន នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី 28 កញ្ញា 1984, E/CN.4/1985/4, អាចរកបាននៅគេហទំព័រ: http://www.refworld.org/docid/4672bc122.html.

[19] សំណុំរឿងក្តី Guy S. Goodwin-Gill, ការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ, សហភាពអន្តរសភា, ទីក្រុងហ្សឺណែវ, ឆ្នាំ ២០០៦, ទំព័រ ១៣៧។

សរុបសេចក្តីមក សម្រាប់ការរឹតត្បិតដែលមានចែងក្នុងច្បាប់អនុញ្ញាតក្រោមបទដ្ឋានអន្តរជាតិដែលកំពុងអនុវត្ត ការរឹតត្បិតទាំងនោះ គួរតែត្រូវបានបរិយាយឲ្យបានជាក់លាក់បន្ថែមទៀត។ ដំណើរការដែលការរឹតត្បិតអាចត្រូវបានអនុវត្តក្នុងករណីជាក់លាក់មួយចំនួន ក៏គួរតែចាំបាច់ត្រូវកំណត់ឲ្យបានជាក់លាក់ផងដែរ និងប្រគល់ភារកិច្ចនេះឲ្យទៅស្ថាប័នមួយគ្រប់គ្រងដោយឯករាជ្យ។ បើតាមគណៈកម្មាធិការសិទ្ធិមនុស្ស បន្ទុកភស្តុតាងត្រូវធ្លាក់ទៅលើរដ្ឋដែលជាអ្នកត្រូវពន្យល់ថា ហេតុអ្វីបានជាការរឹតត្បិតណាមួយដែលបានដាក់ចេញនោះ គឺជាការចាំបាច់។[20]

[20] សូមមើលបណ្តឹងលេខ1383/2005, សំណុំរឿងក្តី Katsora et al. v. Belarus, ទស្សនៈ ត្រូវបានអនុម័តនៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១០ និង បណ្តឹងលេខ 2165/2012, សំណុំរឿងក្តី Pinchuk v. Belarus, ទស្សនៈ ត្រូវបានអនុម័តនៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៤, ក្នុងចំណោមសេចក្តីសម្រេចផ្សេងទៀតរបស់គណៈកម្មាធិការសិទ្ធិមនុស្ស។ សូមមើលផងដែរនូវសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ២៥។

## III. សេចក្តីវិភាគលើច្បាប់ស្តីពីគណបក្សនយោបាយ

សេចក្តីវិភាគនេះ គ្របដណ្តប់លើមាត្រាទាំងឡាយនៃសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលមានផលប៉ះពាល់ដល់សិទ្ធិមនុស្ស ដូចមានរាយនៅក្នុងមាតិកានេះ។ មាត្រាភាគច្រើនផ្សេងទៀតដែលការិយាល័យ OHCHR មិនផ្តល់មតិយោបល់ គឺមិនមានសរសេរនៅទីនេះទេ ហើយការដែលរក្សាទុកមាត្រាមួយចំនួននៅទីនេះ គឺគ្រាន់តែសម្រាប់ងាយស្រួលយោងតែប៉ុណ្ណោះ ដើម្បីជួយសម្រួលដល់ការយល់ដឹងអំពីមាត្រាទាំងនោះដែលត្រូវបានវិភាគ ហើយដែលរួមបញ្ចូលជាសេចក្តីយោងទៅមាត្រាទាំងនោះ។ សេចក្តីវិភាគនេះ គឺផ្អែកលើអត្ថបទបកប្រែជាភាសាអង់គ្លេសមិនផ្លូវការនៃច្បាប់វិសោធនកម្មដែលបានរៀបចំឡើងដោយការិយាល័យ OHCHR ។

**មាត្រា៥.-**

ការចូលជាសមាជិករបស់គណបក្សនយោបាយណាមួយ គឺជាការជ្រើសរើសផ្ទាល់ខ្លួនដោយសេរីរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។ គ្មានជនណាម្នាក់ មានសិទ្ធិបង្ខិតបង្ខំឲ្យគេចូលជាសមាជិកគណបក្សនយោបាយណាមួយឡើយ។

គ្មានជនណាម្នាក់ត្រូវបានគេដកហូតសិទ្ធិក្នុងការអនុវត្តសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ ឬសិទ្ធិវិជ្ជាជីវៈ ដោយសារមូលហេតុជននោះ ជាសមាជិក ឬមិនមែនជាសមាជិករបស់គណបក្សនយោបាយណាមួយ ដែលបង្កើតឡើងដោយស្របច្បាប់នោះទេ។

**មាត្រា៦.- ថ្មី**

គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយ ដូចខាងក្រោម ៖

១. ធ្វើឲ្យមានអបគមន៍ ដែលនាំឲ្យអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី។

២. ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

៣. ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ។

៤. បង្កើតកម្លាំងប្រដាប់អាវុធ។

៥. ធ្វើការញុះញង់ដែលអាចនាំឲ្យមានការបែកបាក់ជាតិ។

**មតិយោបល់៖** ពាក្យពេចន៍មិនច្បាស់លាស់ និងស្រពិចស្រពិលក្នុងកថាខណ្ឌទី១, ២, ៣ និងទី៥ អាចនាំឲ្យមានការបកស្រាយជាអត្តនោម័ត ដូច្នេះហើយ វាកម្រិតកំណត់សិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋ ដែលបានប្រើប្រាស់តាមរយៈគណបក្សនយោបាយ។ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ទាមទារឲ្យមានភាពច្បាស់លាស់នៅក្នុងច្បាប់។ គោលការណ៍ណែនាំរបស់គណៈកម្មការទីក្រុងវីនីស ស្តីពីបទប្បញ្ញត្តិគណបក្សនយោបាយ ចែងថាច្បាប់ស្តីពីគណបក្សនយោបាយ ត្រូវតែច្បាស់លាស់ និងជាក់លាក់សម្រាប់គណបក្សនយោបាយ ទាំងសកម្មភាពដែលចាត់ទុកថាមិនស្របច្បាប់ និងទោសទណ្ឌដែលត្រូវអនុវត្ត ក្នុងករណីមានការរំលោភបំពាន។[21] ទោះបីជាកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) អនុញ្ញាតឲ្យមានការកម្រិតកំណត់សិទ្ធិមួយចំនួនក្តី ក៏ការម្រិតកំណត់នេះ ត្រូវតែស្របតាមកាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់អន្តរជាតិផងដែរ។[22] មាត្រា៥ នៃកតិកាសញ្ញា ICCPR បញ្ជាក់ច្បាស់បន្ថែមទៀតថា មិនមានការប្រគល់ឲ្យរដ្ឋនូវ "សិទ្ធិក្នុងការលូកដៃចូលក្នុងសកម្មភាព ឬការអនុវត្តកិច្ចការណាមួយដែលសំដៅបំផ្លាញសិទ្ធិសេរីភាពណាមួយនៅទីនេះ ឬការកម្រិតដែនកំណត់លើសិទ្ធិសេរីភាពទាំងនោះលើសពីអ្វីដែលមានចែងក្នុងកតិកាសញ្ញានេះឡើយ។"

សេរីភាពក្នុងការបញ្ចេញមតិ និងខាងសមាគម ជាកម្មសិទ្ធិរបស់មនុស្សគ្រប់រូប ដោយមិនគិតពីអាយុ សញ្ជាតិ និន្នាការនយោបាយ ឬស្ថានភាពផ្សេងទៀតរបស់ពួកគេឡើយ។ បើតាមគណៈកម្មាធិការសិទ្ធិមនុស្ស "គោលបំណងស្របច្បាប់នៃការធានាការពារ និងការពង្រឹងឯកភាពជាតិពិតប្រាកដដែលស្ថិតក្រោមកាលៈទេសៈនយោបាយដ៏លំបាក មិនអាចសម្រេចបានតាមរយៈការព្យាយាមបិទមិនឲ្យមានការតស៊ូមតិនៃលទ្ធិប្រជាធិបតេយ្យពហុបក្ស ទស្សនៈលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនោះទេ ... "។[23]

មាត្រា៦ ថ្មី ទំនងជាលើកកម្ពស់គោលការណ៍ធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា១ នៃរដ្ឋធម្មនុញ្ញថា ប្រទេសកម្ពុជាប្រត្តិបត្តិតាម " គោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស" ដែលត្រូវបានពង្រឹងបន្ថែមក្នុងមាត្រា៥១ ដែលចែងថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស" ហើយថា "ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសខ្លួន។" ការចែងដូច្នេះ សំដៅបង្ការទប់ស្កាត់គណបក្សនយោបាយ មិនឲ្យធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។" ដើម្បីធានាថា មាត្រា៦ នឹងត្រូវបានពង្រឹងអនុវត្តតាមរបៀបមួយដែល

---

[21] គោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិគណបក្សនយោបាយរបស់ OSCE ទំព័រ ១០។

[22] សូមមើលផ្នែកខាងលើ ស្តីពី "ការរឹតត្បិតដែលអនុញ្ញាត្តិលើសិទ្ធិមនុស្ស"។

[23] សូមមើលបណ្តឹងលេខ 458/91, សំណុំរឿងក្តី Mukong v. Cameroon, ទស្សនៈ ត្រូវបានអនុម័តនៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ១៩៩៤។

លើកកម្ពស់របបប្រជាធិបតេយ្យសេរីពហុបក្ស និងប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ គឺតម្រូវឲ្យមានភាពច្បាស់លាស់អំពីសកម្មភាពជាក់លាក់មួយចំនួន ដែលចាត់ទុកថាជាការបំពានលើមាត្រា៦នេះ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យកែសម្រួលពាក្យ "ឯកភាពជាតិ" " ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ" និង "សន្តិសុខនៃរដ្ឋ" ឬកំណត់និយមន័យពាក្យទាំងនេះ អំពីសកម្មភាពច្បាស់លាស់ដែលត្រូវធ្វើការហាមឃាត់ ដើម្បីធានាថាបុគ្គលជាសមាជិកនៃគណបក្សនយោបាយណាមួយ អាចយល់ដឹងពេញលេញអំពីសកម្មភាពដែលត្រូវហាមឃាត់ ហើយអនុវត្តសិទ្ធិរបស់ខ្លួនដោយមិនមានការរឹតត្បិតជ្រុលពេក ឬវិសមមាត្រភាព។

មាត្រា៧.-

គ្រប់គណបក្សនយោបាយ មិនត្រូវស្ថិតនៅក្រោមចំណុះ ឬការបង្គាប់បញ្ជារបស់គណបក្សនយោបាយបរទេស ឬរបស់រដ្ឋាភិបាលបរទេស។

មាត្រា៩.-

ប្រជាពលរដ្ឋខ្មែរចំនួនយ៉ាងតិច ៨០នាក់ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ ហើយដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិផ្តើមបង្កើតគណបក្សនយោបាយមួយបាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខអក្សរទៅក្រសួងមហាផ្ទៃ។ ក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបជាលាយលក្ខអក្សរថាបានទទួលសេចក្តីជូនដំណឹងនេះ ក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ។ បើហួសការកំណត់ ១៥ថ្ងៃនេះ ត្រូវចាត់ទុកថាបានទទួលសេចក្តីជូនដំណឹងនេះ។

គណបក្សនយោបាយដែលទើបផ្តើមបង្កើត ត្រូវធ្វើការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការបណ្តោះអាសន្នដែលមានសមាជិកយ៉ាងតិច ៧រូប ហើយដែលម្នាក់ៗមានអាយុយ៉ាងតិច ២៥ឆ្នាំ សម្រាប់រៀបចំបែបបទ និងបំពេញល័ក្ខខ័ណ្ឌនៃការសុំចុះបញ្ជីគណបក្សនយោបាយតាមការកំណត់ដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ដើម្បីទទួលបានសុពលភាព។

ទោះបីមិនទាន់ទទួលបានសុពលភាពក៏ដោយ ក្នុងរយៈពេលនេះ គណបក្សនយោបាយអាចលើកផ្លាកនៅទីស្នាក់ការរបស់ខ្លួនបាន។

មាត្រា១០.-

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំលក្ខន្តិកៈ និងគោលនយោបាយសំខាន់ៗជាលាយលក្ខអក្សរ ដែលមានចំណុចសំខាន់ៗយ៉ាងតិចណាស់ដូចខាងក្រោមនេះ៖

ក. លក្ខន្តិកៈត្រូវមាន ៖

១. ឈ្មោះជាអក្សរពេញ អក្សរកាត់និងសញ្ញាសំគាល់។

២. អាស័យដ្ឋាននៃទីស្នាក់ការកណ្តាល។

៣. កាលបរិច្ឆេទនៃការបង្កើតគណបក្សនយោបាយ។ កាលបរិច្ឆេទគណបក្សនយោបាយនេះ មិនត្រូវជាន់លើថ្ងៃបុណ្យជាតិនិងអន្តរជាតិ។

៤. វិធានស្តីពីការបញ្ចូលជាសមាជិកភាពនិងការបណ្តេញចេញពីសមាជិកភាព។

៥. សិទ្ធិនិងភារកិច្ចរបស់សមាជិក។

៦. រចនាសម្ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមបន្តបន្ទាប់។

៧. សមត្ថកិច្ចនៃអង្គការនានារបស់គណបក្សនយោបាយ។

៨. បែបបទនៃការជ្រើសរើសនិងដកហូតមុខងាររបស់សមាជិកគណកម្មាធិការនាយក។

៩. ការកំណត់អំពីការប្រជុំសាមញ្ញ នៃអង្គការនានារបស់គណបក្សនយោបាយ។

១០. ចំនួនសមាជិកចាំបាច់ " កូរ៉ុម " ដែលត្រូវចូលរួមក្នុងអង្គប្រជុំនៃអង្គការនានារបស់គណបក្សនយោបាយ ដើម្បីឲ្យអង្គប្រជុំនោះយកជាការបាន។

១១. ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ។

១២. វិធានស្តីពីការរំលាយគណបក្សនយោបាយនិងការចាត់ចែងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ នៅពេលត្រូវរំលាយ។

១៣. វិធានស្តីពីការធ្វើវិសោធនកម្មលក្ខន្តិកៈគណបក្សនយោបាយ។

ខ. គោលនយោបាយនិងកម្មវិធីនយោបាយសំខាន់ៗ ត្រូវចែងអំពីគោលដៅនិងវត្ថុបំណងរបស់គណបក្សនយោបាយ។

**មាត្រា១២.- ថ្មី**

មានតែប្រជាពលរដ្ឋខ្មែរ ដែលមានអាយុយ៉ាងតិច ១៨(ដប់ប្រាំបី)ឆ្នាំ និងមានសិទ្ធិពលរដ្ឋប៉ុណ្ណោះ ដែលអាចចូលជាសមាជិកគណបក្សនយោបាយបាន។

**មតិយោបល់៖** ចំពោះសេចក្តីស្នើច្បាប់នេះ មាត្រា១២ ថ្មី ចែងពីការរារាំងបុគ្គលមួយចំនួនមិនឲ្យក្លាយជាសមាជិកនៃគណបក្សនយោបាយ ដោយផ្អែកលើហេតុផលចំនួនបី៖ សញ្ជាតិ អាយុ និងទាល់តែបុគ្គលនោះ "មានសិទ្ធិពលរដ្ឋ"។ បញ្ញត្តិនេះផ្ទុយនឹងមាត្រា២២ នៃកតិកាសញ្ញាICCPR ដែលចែងថា "*មនុស្សគ្រប់រូប*មានសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមជាមួយអ្នកដទៃ" (បញ្ជាក់បន្ថែម) លុះត្រាណាតែការរឹតត្បិតនោះមានលក្ខខណៈតូចចង្អៀត ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រាដដែលនេះ។[24]

សិទ្ធិក្នុងការចូលរួម ឬចូលជាសមាគមជាមួយគណបក្សនយោបាយមួយ គឺជាសិទ្ធិរបស់បុគ្គលគ្រប់រូប ដោយមិនគិតពីសញ្ជាតិ និងអាយុ ហើយគួរតែញែកឲ្យដាច់ពីសិទ្ធិបោះឆ្នោត ដែលអាចត្រូវបានកម្រិតកំណត់ដោយស្របច្បាប់ ចំពោះប្រជាពលរដ្ឋដែលមានអាយុមួយជាក់លាក់។ បើយោងតាមអ្នករាយការណ៍ពិសេសស្តីពីសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងក្នុងការបង្កើតសមាគម ការតាក់តែងច្បាប់ស្តីពីសេរីភាពក្នុងការបង្កើតសមាគម មិនគួរធ្វើការកម្រិតកំណត់ជាក់លាក់ទៅលើបុគ្គលឡើយ រាប់ទាំងកុមារ និងជនបរទេសផងដែរ[25] លើកលែងតែក្នុងករណីនៃបុគ្គលដែលជាប់កាតព្វកិច្ចខាងវិជ្ជាជីវៈដែលត្រូវគោរពអព្យាក្រឹតភាពនយោបាយ (សូមមើលមតិយោបល់របស់ការិយាល័យ OHCHR នៅមាត្រា១៨ ថ្មី) ។

គណបក្សនយោបាយ គឺជាយន្តការមួយសំខាន់សម្រាប់ការប្រើប្រាស់សិទ្ធិនយោបាយ សម្រាប់ការសន្ទនាគ្នាអំពីគោលនយោបាយ និងបញ្ហាអាទិភាពថ្នាក់ជាតិ និងសម្រាប់ការចែករំលែកចក្ខុវិស័យសម្រាប់ថ្ងៃអនាគតក្នុងចំណោមបុគ្គលដែលមានគំនិតដូចគ្នា មិនត្រឹមតែនៅក្នុងពេលបោះឆ្នោតប៉ុណ្ណោះទេ គឺសម្រាប់ពេលបន្តទៅមុខទៀត។ មិនមានហេតុផលច្បាស់ថា ហេតុអ្វីបានជាយុវជន មិនគួរត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងគណបក្សនយោបាយ ហើយជាការពិតណាស់ ដែលគណបក្សជាច្រើននៅទូទាំងពិភពលោក រក្សាទុកយុវជនសម្រាប់គោលបំណងអប់រំ។

ភាពមិនច្បាស់លាស់ជុំវិញពាក្យពេចន៍ "សិទ្ធិពលរដ្ឋ" ដែលអនុញ្ញាតឲ្យមានវិសាលភាពសម្រាប់

[24] សូមមើលផ្នែកខាងលើ ស្តីពី "ការរឹតត្បិតដែលអនុញ្ញាត្តិលើសិទ្ធិមនុស្ស"។

[25] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងខាងសមាគម ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប លេខ A/HRC/20/27, កថាខណ្ឌ ៥៤ និង លេខ A/HRC/26/29, កថាខណ្ឌ ១៨។

បុគ្គលមួយចំនួន ដែលអាចត្រូវបានគេបដិសេធសិទ្ធិក្នុងការក្លាយជាសមាជិកគណបក្សនយោបាយមួយ គួរតែត្រូវបានកាត់បន្ថយ តាមរយៈការកំណត់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ដែលកំណត់សិទ្ធិពលរដ្ឋជាក់លាក់ដែលបុគ្គលម្នាក់ត្រូវតែមាន ដើម្បីអាចក្លាយជាសមាជិកគណបក្សនយោបាយមួយ។ ជាឧទាហរណ៍ វាមិនទាន់ច្បាស់ថាតើ "សិទ្ធិពលរដ្ឋ" ដែលមានចែងក្នុងមាត្រា១២ ថ្មី រួមបញ្ចូលសិទ្ធិកាន់តំណែងជាអ្នកដឹកនាំក្នុងគណបក្សនយោបាយមួយ ក្រោមមាត្រា១៨ ថ្មីឬទេ ដូច្នេះប្រសិនជាមានបុគ្គលណាមួយបាត់បង់តំណែងតួនាទីរបស់ខ្លួន គាត់ក៏ត្រូវតែសុំលាឈប់ពីគណបក្សផងដែរ។ ប្រសិនជាការនេះសំដៅដល់សិទ្ធិដែលបានកំណត់ក្រោមមាត្រា៥៥ នៃក្រមព្រហ្មទណ្ឌ មាត្រានេះគួរតែចែងដូច្នេះ។

ជាចុងក្រោយ អ្នករាយការណ៍ពិសេសស្តីពីសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងខាងសមាគម បានគូសបញ្ជាក់ថា " សមាសធាតុមួយដ៏សំខាន់នៃសិទ្ធិសេរីភាពខាងសមាគម នោះគឺថា គ្មាននរណាម្នាក់អាចនឹងត្រូវបានគេបង្ខំឲ្យចូលជាសមាជិកសមាគមណាមួយឡើយ។"[26] ដោយហេតុថា គណបក្សនយោបាយ ជាសំណុំមួយនៃសមាគម ដូច្នេះលក្ខខណ្ឌដូចគ្នានេះ ក៏ត្រូវអនុវត្តផងដែរចំពោះគណបក្សនយោបាយ៖ សិទ្ធិសេរីភាពខាងសមាគមគ្របដណ្តប់ត្រឡប់មកវិញ មិនត្រូវបង្ខំបុគ្គលណាមួយឲ្យចូលគណបក្សនយោបាយដោយផ្ទុយនឹងឆន្ទៈរបស់ខ្លួនឡើយ។

**ការិយាល័យ OHCHR សូមផ្តល់ជាអនុសាសន៍**ស្នើឲ្យមានការលុបចោលមាត្រា១២ ថ្មី ហើយដាក់ជំនួសវិញនូវឃ្លាខាងក្រោមនេះ៖ *"គ្មាននរណាម្នាក់ អាចត្រូវបានបង្ខំឲ្យចូលរួម ឬបង្កើតជាសមាគមជាមួយគណបក្សនយោបាយណាមួយឡើយ។"*

**មាត្រា១៥.-**

ប្រជាពលរដ្ឋខ្មែរម្នាក់ មិនអាចជាសមាជិកគណបក្សនយោបាយលើសពីមួយក្នុងពេលតែមួយបានទេ។ ក្នុងករណីដែលបុគ្គលមួយរូបចូលជាសមាជិកគណបក្សនានាយ៉ាងច្រើន សមាជិកភាពក្នុងគណបក្សនយោបាយចុងក្រោយ ត្រូវចាត់ទុកជាបានការ។

បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ អាចចូលជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ។ គណបក្សនយោបាយ មិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិទេ។

---

[26] របាយការណ៍លេខ A/HRC/20/27, កថាខណ្ឌ ៥៥។

**មាត្រា១៧.- ថ្មី**

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឲ្យមានអង្គការដឹកនាំយ៉ាងតិចដូចខាងក្រោម៖

១. មហាសន្និបាត ឬសមាជ ឬអង្គការសមមូល។

២. ក្រុមប្រឹក្សាជាតិ ឬគណៈកម្មាធិការកណ្តាល ឬអង្គការសមមូល។

៣. គណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូល។

៤. គណៈកម្មាធិការអាជ្ញាកណ្តាល ឬគណៈកម្មាធិការត្រួតពិនិត្យ ឬគណៈកម្មាធិការវិវាទ ឬអង្គការសមមូល ។

ឈ្មោះអង្គការដឹកនាំរបស់គណបក្សនយោបាយគ្រប់ជាន់ថ្នាក់នេះ អាចប្រែប្រួលអាស្រ័យទៅតាមការកំណត់របស់លក្ខន្តិកៈនៃគណបក្សនយោបាយនីមួយៗ។

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឲ្យមានប្រធាន និងអាចមានអនុប្រធានតាមការចាំបាច់។ ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ ត្រូវជ្រើសរើសដោយអនុវត្តតាមលក្ខន្តិកៈនៃគណបក្សនយោបាយនីមួយៗ។

អាណត្តិ ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗដូចមានចែងខាងលើនេះ ព្រមទាំងអង្គការដឹកនាំផ្សេងទៀតរបស់គណបក្សនយោបាយត្រូវកំណត់ក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ។

**មតិយោបល់**: គណបក្សនយោបាយ និងសមាជិកភាពក្នុងគណបក្សនយោបាយ ដើរតួនាទីដ៏សំខាន់ក្នុងការដឹកនាំកិច្ចការសាធារណៈ និងដំណើរការបោះឆ្នោត។ ក្នុងការគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន គណបក្សនយោបាយទាំងអស់ត្រូវតែគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ ដើម្បីចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈ និងដើម្បីឈរឈ្មោះបោះឆ្នោត ដូចបានកំណត់ដោយគណៈកម្មាធិការសិទ្ធិមនុស្ស តាមរយៈការបង្កើតកាលានុវត្តភាពពិតប្រាកដសម្រាប់ការចូលរួមបែបនេះ។[27] នៅឆ្នាំ២០១២ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាបានសម្តែងកង្វល់ថា៖ "គណបក្សនយោបាយកម្ពុជាភាគច្រើនមិនមានការបញ្ញត្តិទុក ហើយជាទូទៅមិនមាននីតិវិធីបែបប្រជាធិបតេយ្យយ៉ាងច្បាស់សម្រាប់ការជ្រើសរើសបេក្ខជនឡើយ។ មេដឹកនាំគណបក្សគ្រប់គ្រងបេក្ខជនក្នុងបញ្ជី ដែលធ្វើឲ្យបេក្ខជនត្រូវមានភក្តីភាពឬ ស្មោះត្រង់ចំពោះមេដឹកនាំគណបក្សច្រើនជាង ចំពោះម្ចាស់ឆ្នោតរបស់ខ្លួន។ ការរបនេះ អាច

---

[27] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ២៥ កថាខណ្ឌ ២៦។

នឹងនាំឲ្យមានការដកបេក្ខជនចេញពីបញ្ជីដោយបំពាន មានន័យថា បន្ទាប់មកពួកគេត្រូវបាត់បង់អាសនៈរបស់ខ្លួន។ ការរួមផ្សំគ្នានៃប្រព័ន្ធបញ្ជីគណបក្ស និងប្រព័ន្ធបោះឆ្នោតតំណាងសមាមាត្រ ក្នុងរដ្ឋសភា ក៏ជាតំណខ្សោយបំផុតក្នុងប្រព័ន្ធអភិបាលកិច្ចនៅកម្ពុជាផងដែរ។”[28]

**ការិយាល័យ OHCHR សូមផ្តល់ជាអនុសាសន៍ថា** សូមឲ្យដាក់បញ្ចូលប្រយោគខាងក្រោមនេះ នៅខាងចុងបញ្ចប់នៃមាត្រានេះ៖ *"ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការដឹកនាំ ត្រូវធ្វើឡើងតាមបែបប្រជា ធិបតេយ្យ និងគោរពសិទ្ធិមនុស្សរបស់សមាជិករបស់ខ្លួន ជាពិសេស សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ ដោយស្មើភាពគ្នា និងដោយគ្មានការរើសអើង។"*

### មាត្រា១៨.- ថ្មី

ពលរដ្ឋទាំងពីរភេទ ដែលមានសញ្ជាតិខ្មែរពីកំណើត និងមានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ អាចធ្វើជាប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬធ្វើជាសមាសភាពនៃអង្គការដឹកនាំនៃគណបក្សនយោបាយបាន។

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬ គណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការ អចិន្ត្រៃយ៍នៃគណបក្សនយោបាយ មិនត្រូវជាបុគ្គលដែលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈឹម ដោយគ្មានការព្យួរទោសឡើយ។

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬ គណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការ អចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវបាត់បង់នូវតួនាទីរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម៖

- សាមីខ្លួនទទួលមរណភាព។
- សាមីខ្លួនបានសុំលាឈប់ជាលាយលក្ខអក្សរ។
- សាមីខ្លួនត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈឹម ដោយគ្មានការព្យួរទោស លើកលែងតែទោសនោះត្រូវបានលើកលែងទោសដោយព្រះមហាក្សត្រ។

[28] របាយការណ៍លេខ A/HRC/21/63, កថាខណ្ឌ ៥៤។

គណបក្សនយោបាយ ត្រូវចាត់នីតិវិធីដើម្បីជំនួសប្រធានគណបក្សនយោបាយដែលបាត់តួនាទី ដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្នុងរយៈពេលយ៉ាងយូរ ៩០ (កៅសិប)ថ្ងៃ គិតពីថ្ងៃបាត់បង់តួនាទីនោះ។

បទប្បញ្ញត្តិនេះ ក៏ត្រូវយកទៅអនុវត្តផងដែរចំពោះបុគ្គលដែលមានតួនាទី ឬសិទ្ធិអំណាចប្រហាក់ប្រហែលទៅនឹងប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ។

**មតិយោបល់**: ការិយាល័យ OHCHR យល់ស្របថា បុគ្គលគ្រប់រូបរាប់ទាំងអ្នកដែលមានបំណងដឹកនាំគណបក្សនយោបាយផងដែរ គួរតែគោរពច្បាប់ និងទទួលស្គាល់ថា ការរឹតត្បិតមួយចំនួនគឺអនុញ្ញាតក្រោមច្បាប់សិទ្ធិមនុស្ស។ [29] របៀបដែលការរឹតត្បិតអនុវត្តចំពោះកត្តាជាក់លាក់មួយចំនួនដូចមានចែងក្នុងមាត្រានេះ ត្រូវបានបង្ហាញដូចខាងក្រោមនេះ។

***ការរឹតត្បិតដោយផ្អែកលើសញ្ជាតិពីកំណើត***

ដោយហេតុថា បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ មិនអនុញ្ញាតឲ្យមានការប្រព្រឹត្តផ្សេងពីគ្នារវាងពលរដ្ឋដែលទទួលបានសញ្ជាតិតាមរយៈកំណើត ឬពលរដ្ឋដែលទទួលបានសញ្ជាតិតាមរយៈសញ្ជាតូបនីយកម្មនោះ ប្បញ្ញត្តិនេះ អាចចាត់ទុកជាទម្រង់មួយនៃការរើសអើង។ ប្បញ្ញត្តិនេះ ក៏មានវិសមិតភាពផងដែរទៅនឹងរដ្ឋធម្មនុញ្ញកម្ពុជា ដែលមិនអនុញ្ញាតឲ្យមានការប្រព្រឹត្តផ្សេងគ្នារវាងពលរដ្ឋទាំងពីរប្រភេទនេះ។ បើតាមគណៈកម្មាធិការសិទ្ធិមនុស្ស ការញែកចេញពីគ្នារវាងបុគ្គលដែលទទួលបានសញ្ជាតិតាមរយៈកំណើត និងបុគ្គលដែលទទួលបានសញ្ជាតិតាមរយៈសញ្ជាតូបនីយកម្ម អាចចោទជាបញ្ហាអំពីសមិតភាពជាមួយសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ។[30]

***ការរឹតត្បិតដោយផ្អែកលើទោសព្រហ្មទណ្ឌ***

ការចែងយោងដល់ " បទឧក្រិដ្ឋ ឬ បទមជ្ឈឹម" បង្ហាញឲ្យឃើញថា មាត្រា១៨ ថ្មី មានបំណងបង្ការ ឬរារាំងបុគ្គលដែលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈឹម មិនឲ្យធ្វើជា " ប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈ

---

[29] សូមមើលផ្នែកខាងលើ ស្ដីពី "ការរឹតត្បិតដែលអនុញ្ញាត្តិលើសិទ្ធិមនុស្ស"។

[30] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ២៥ កថាខណ្ឌ ៣។

កម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ។" បើតាមគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ការរឹតត្បិតមួយចំនួន អាចអនុញ្ញាតឲ្យធ្វើបាន ប៉ុន្តែចាំបាច់ត្រូវឲ្យមានការវាយតម្លៃអំពី "ភាពសមហេតុផល" លក្ខណៈវិនិច្ឆ័យអំពីភាពចាំបាច់ ភាពសមាមាត្រ និងភាពស្របច្បាប់។[31]

ប្បញ្ញត្តិនេះ អាចមានការជជែកតវ៉ាថា មិនមែនរាល់បទល្មើសមជ្ឈិមទាំងអស់ ដែលមានចែងក្នុងច្បាប់កម្ពុជា សុទ្ធសឹងតែជាបទល្មើសធ្ងន់ធ្ងរ ដែលត្រូវបាត់សិទ្ធិធ្វើជាអ្នកដឹកនាំគណបក្សនយោបាយមួយជីវិតឡើយ។ ក្រមព្រហ្មទណ្ឌ ឆ្លុះបញ្ចាំងពីកម្រិត ឬថ្នាក់នៃទោសព្រហ្មទណ្ឌ ដោយផ្អែកលើភាពធ្ងន់ធ្ងរនៃបទល្មើស ហើយកំណត់បទមជ្ឈិមថាជាបទល្មើសដែលទោសអតិបរមាគឺមានរយៈពេលលើសពីប្រាំមួយថ្ងៃ ប៉ុន្តែមិនលើសពីប្រាំឆ្នាំ[32] ដែលរួមបញ្ចូលទាំងបទល្មើស ដូចជាការបើកបរក្នុងស្ថានភាពស្រវឹង (ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលប្រាំមួយថ្ងៃ ទៅប្រាំមួយខែ និងពិន័យជាប្រាក់) ឬការបើកបរដោយគ្មានស្លាកលេខ ឬមិនឈប់រថយន្តតាមបញ្ជារបស់នគរបាលចរាចរណ៍ (បទល្មើសទាំងពីរនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយថ្ងៃ ទៅមួយខែ និងពិន័យជាប្រាក់)។[33] ផ្ទុយទៅនឹងមាត្រា១៨ ថ្មី ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលច្បាប់នេះដកសិទ្ធិបុគ្គលត្រឹមតែក្នុងការឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រប៉ុណ្ណោះ "ដែលត្រូវបានតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិម *និងមិនទាន់បានស្តារនីតិសម្បទា"* (មាត្រា៣៤ ថ្មី នៃច្បាប់បោះឆ្នោត *ដែលមានការបញ្ជាក់បន្ថែម)* ។

បើតាមទស្សនៈរបស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងខាងសមាគម និងអង្គហេតុដែលថាមានបទល្មើសជាច្រើនដែលអាចរារាំងបុគ្គលមិនឲ្យកាន់មុខតំណែងដូចនេះអស់មួយជីវិត គឺមិនពាក់ព័ន្ធនឹងអំពើហិង្សា ឬការញុះញង់ឲ្យមានការស្អប់ខ្ពើម រួមទាំង "បទលហុ" ផងដែរ ប្បញ្ញត្តិនេះទំនងជាមានការរឹតត្បិតជ្រុលហួសហេតុពេក និង

---

[31] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ២៥ កថាខណ្ឌ ៤ "លក្ខខណ្ឌទាំងឡាយដែលអនុវត្តចំពោះការប្រើប្រាស់សិទ្ធិទាំងឡាយដែលការពារដោយមាត្រា ២៥ គួរតែត្រូវផ្អែកទៅលើលក្ខណៈវិនិច្ឆ័យនៃគោលដៅ និងសមហេតុផល" ។ សូមមើលផ្នែកខាងលើស្តីពី "ការរឹតត្បិតដែលអនុញ្ញាតិលើសិទ្ធិមនុស្ស" ផងដែរ។

[32] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[33] មាត្រា ៧៦ ៧៧ និង ៨២ នៃច្បាប់ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៥។

មិនបំពេញតាមតេស្តមួយអំពីភាពសមហេតុផល ដែលបានតម្រូវក្រោមកតិកាសញ្ញាICCPRឡើយ។[34]

ជាទូទៅ គោលការណ៍ប្រជាធិបតេយ្យបែបទំនើប ផ្តល់សេចក្តីទុកចិត្តលើអ្នកបោះឆ្នោតក្នុងការវិនិច្ឆ័យដោយខ្លួនឯង អំពីភាពសាកសមសម្រាប់តួនាទីជាអ្នកដឹកនាំក្នុងគណបក្សនយោបាយមួយ។ ប្រសិនបើសមាជិកនៃគណបក្សនយោបាយមួយ មិនចង់ឃើញបុគ្គលដែលត្រូវបានតុលាការផ្តន្ទាទោសចូលកាន់តំណែងជាអ្នកដឹកនាំទេនោះ ពួកគេមានសេរីភាពក្នុងការបញ្ចូលវិធាន ឬបញ្ញត្តិមួយនៅក្នុងលក្ខន្តិកៈរបស់ខ្លួនផ្ទាល់ ដូចមានចែងក្នុងមាត្រា១០ នៃច្បាប់ស្តីពីគណបក្សនយោបាយ។ ពួកគេមានសេរីភាពក្នុងការធ្វើជាសមាគមជាមួយអ្នកផ្សេងទៀត ដែលចែករំលែកគោលបំណង មតិយោបល់ និងតម្លៃរបស់ខ្លួន ក៏ដូចជា ការមិនបោះឆ្នោតឲ្យបុគ្គលមួយចំនួន រាប់ទាំងអ្នកដែលអាចមានឈ្មោះក្នុងលិខិតថ្កោលទោសជាដើម ប៉ុន្តែការនេះមិនគួរត្រូវបានកំណត់ដោយច្បាប់ឡើយ។ ករណីអញ្ញត្រកម្មមួយចំនួននៅក្នុងវិធានទូទៅនេះ ត្រូវបានអនុញ្ញាតស្ថិតក្រោមលក្ខខណ្ឌជាក់លាក់មួយចំនួន ដូចបានគូសបញ្ជាក់កន្លងមក ដូចជា ក្នុងករណីនៃបុគ្គលដែលញុះញង់ឲ្យមានអំពើហិង្សា ការរើសអើង ឬការស្អប់ខ្ពើមអ្នកដទៃទៀតជាដើម។[35]

ម្យ៉ាងវិញទៀត មានបុគ្គលមួយចំនួន ត្រូវបានផ្តន្ទាទោសកាលពីពេលដែលពួកគេនៅជាអនីតិជននៅឡើយ។ ចំណុចនេះ គួរតែបានពិចារណាពីសុពលភាពនៃការហាមឃាត់មិនឲ្យកាន់មុខតំណែងជាអ្នកដឹកនាំគណបក្សនយោបាយអស់មួយជីវិត ដោយសារតែបទល្មើសដែលពួកគេបានប្រព្រឹត្តនោះកើតឡើងនៅមុនពេលដែលពួកគេមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ថាជានីតិជន។ ក្នុងន័យនេះ គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ថា រដ្ឋភាគី ត្រូវតែលុបឈ្មោះកុមារដែលបានប្រព្រឹត្តបទល្មើសចេញពីលិខិតថ្កោលទោសដោយស្វ័យប្រវត្តិ នៅពេលដែលពួកគេមានអាយុ១៨ ឆ្នាំ។[36]

ជាទូទៅ គណបក្សនយោបាយគួរតែគ្រប់គ្រងដោយខ្លួនឯង ទន្ទឹមពេលដែលត្រូវធានាថាពួកគេត្រូវគោរពសិទ្ធិ និងកាលានុវត្តភាពរបស់ប្រជាពលរដ្ឋ ក្នុងការចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈ និងឈរឈ្មោះឲ្យគេបោះឆ្នោត ដូចដែលបានកំណត់ ដោយគណៈកម្មាធិការសិទ្ធិមនុស្ស។ [37] គោលការណ៍ដូចគ្នានេះ ក៏គួរតែអនុវត្តផងដែរចំពោះបញ្ហានៃការដាក់ជំនួសតំណែងទំនេរក្នុងថ្នាក់ដឹកនាំ។

---

[34] សូមមើលបណ្តឹងលេខ 1410/2005, សំណុំរឿងក្តី Yevdokimov និង Rezanov v Russian Federation, កថាខណ្ឌ ៧, ៥ ស្តីពីបញ្ហាភាពសមហេតុផលទាក់ទងនឹងការរឹតត្បិតគ្រប់ទិដ្ឋភាព នៃមាត្រា២៥ នៃកតិកាសញ្ញា ICCPR. សូមមើលផ្នែកខាងលើស្តីពី "ការរឹតត្បិតដែលអនុញ្ញាត្តិលើសិទ្ធិមនុស្ស" ។

[35] សូមមើលផ្នែកខាងលើស្តីពី "ការរឹតត្បិតដែលអនុញ្ញាត្តិលើសិទ្ធិមនុស្ស" ។

[36] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិកុមាររបស់ អ.ស.ប លេខ ១០, CRC/C/GC/10, កថាខណ្ឌ ៦៧។

[37] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ២៥ កថាខណ្ឌ ២៦។

បញ្ហានេះត្រូវបានលើកឡើងនៅក្នុងមាត្រា១០ នៃច្បាប់នេះ ដែលតម្រូវឲ្យគណបក្សនយោបាយនីមួយៗ បង្កើតច្បាប់លក្ខន្តិកៈរបស់ខ្លួនផ្ទាល់ និងគោលនយោបាយសំខាន់ៗ រាប់ទាំងបែបបទនៃការជ្រើសរើស និងដកហូតមុខងាររបស់សមាជិកគណៈកម្មាធិការនាយក ហើយក៏ត្រូវប្បញ្ញត្តិការហាមឃាត់ណាមួយ មិនឲ្យកាន់មុខតំណែងនៅគណបក្សនយោបាយផងដែរ។

ទំលាប់អនុវត្តន៍ជាអន្តរជាតិ បង្ហាញពីសំណុំនៃរបៀបដែលអាចធ្វើឲ្យកង្វល់ផ្នែកសន្តិសុខមាន តុល្យភាពប្រសើរឡើង ទន្ទឹមនឹងការគោរពសិទ្ធិមនុស្ស។ ជាជាងការបង្កើតឲ្យមានការដកហូតសិទ្ធិដាច់ខាត វាបង្ហាញផលវិបាកច្រើនទៀតអំពីសមាមាត្រចំពោះបទល្មើស៖ ឧទាហរណ៍ ការដាក់ការរឹតត្បិតតែទៅលើបទល្មើសធ្ងន់ធ្ងរបំផុត ដែលត្រូវតែបញ្ជាក់ ឬកំណត់ឲ្យបានត្រឹមត្រូវ, ការចងភ្ជាប់ភាពធ្ងន់ធ្ងរនៃការរឹតត្បិតទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើស ឧទាហរណ៍ ការកម្រិតកំណត់ការរឹតត្បិតចំពោះបទល្មើសដែលជាកម្មវត្ថុនៃការផ្តន្ទាទោសជាអប្បបរមា, ការបញ្ជាក់ថា ការដកហូតសិទ្ធិនេះ មិនត្រូវអនុវត្តទេ ប្រសិនបើទោសនោះរួមបញ្ចូលជម្រើសនៃការបង់ប្រាក់ពិន័យ ជំនួសឲ្យការដាក់ទោសជាប់ពន្ធនាគារ, និងឬ ការកំណត់អំពីពេលកំណត់លើការដកសិទ្ធិ។

### *ការខកខានចែងអ្នកផ្សេងទៀត ដែលគួរតែត្រូវបានហាមឃាត់ពីមុខតំណែងដឹកនាំគណបក្សនយោបាយ*

មាត្រា១៨ ថ្មី មិនបានចែងដល់អ្នកផ្សេងទៀតដែលគួរតែត្រូវបានរារាំងដោយស្របច្បាប់ពីការកាន់មុខតំណែងដឹកនាំនៅក្នុងគណបក្សនយោបាយ ដោយសារតែភារកិច្ចវិជ្ជាជីវៈរបស់ខ្លួន នៅក្នុងការពង្រឹងអនុវត្តច្បាប់ ដោយត្រូវរក្សាអព្យាក្រឹត និងភាពមិនលំអៀង និងអំពីសារៈសំខាន់នៃការត្រូវបានគេមើលឃើញថាត្រូវធ្វើដូច្នេះ។ បុគ្គលទាំងនេះ អាចរាប់បញ្ចូលទាំងអ្នកដែលកំពុងកាន់មុខតំណែងជាអ្នកដឹកនាំនៅក្នុងកងកម្លាំងប្រដាប់អាវុធ ស្ថាប័នអនុវត្តច្បាប់ (រួមទាំងនគរបាល ចៅក្រម និងព្រះរាជអាជ្ញា) ព្រមទាំងស្ថាប័នត្រួតពិនិត្យឯករាជ្យ ដែលគួរតែបម្រើការជាអ្នកត្រួតពិនិត្យលើអង្គទាំងអស់របស់រដ្ឋាភិបាល ដូចជាស្ថានប័នប្រឆាំងអំពើពុករលួយ ស្ថាប័នសិទ្ធិមនុស្សជាតិ ឬតុលាការរដ្ឋធម្មនុញ្ញ។ កង្វល់នេះត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញដែលចែងថា "អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។"[38] បុគ្គលទាំងនេះ ក៏គួរតែរួមបញ្ចូលផងដែរ នូវអ្នកដែលកំពុងកាន់មុខងារទាំងឡាយ ដូចជាការផ្តល់ឲ្យពួកគេនូវសមត្ថភាព និងអំណាច ដែលអាចចាត់ចែងប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ ក៏ដូចជាបុគ្គលិកធ្វើសកម្មភាពគាំទ្រគណបក្សណាមួយ ប្រសិនជាពួកគាត់ចង់ធ្វើ។ ការរឹតត្បិតដូចនេះ គួរតែស្របតាមសេចក្តីប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោត

---

[38] មាត្រា ៥១ កថាខណ្ឌ៤ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

ដោយសេរី និងយុត្តិធម៌ របស់សហភាពអន្តរសភា ដែលមាត្រា ៤.១ នៃសេចក្តីប្រកាសនេះ ចែងថា វាគឺជាការទទួលខុសត្រូវរបស់រដ្ឋ ដើម្បី"ធានាឲ្យមានការចែកឲ្យដាច់ពីគ្នារវាងគណបក្ស និងរដ្ឋ ហើយបង្កើតលក្ខខណ្ឌសម្រាប់ការប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយផ្អែកលើមូលដ្ឋានសមធម៌។"[39]

ច្បាប់ជាតិក៏បានចែងពីការហាមប្រាមផងដែរ។ ច្បាប់ស្តីពីលក្ខន្តិកៈយោធិន ហាមប្រាមយោធិនទាំងឡាយមិនឲ្យប្រើប្រាស់មុខងាររបស់ខ្លួន និងសម្បត្តិរដ្ឋ ដើម្បីបំរើឲ្យសកម្មភាពនយោបាយណាមួយឡើយ (មាត្រា៩) ។ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល បានផ្តល់សិទ្ធិឲ្យមន្ត្រីរាជការអាចក្លាយជាសមាជិក ឬចូលរួមក្នុងការគ្រប់គ្រងសមាគមស្របច្បាប់ណាមួយបាន (មាត្រា៣៦)។ ទោះជាយ៉ាងណាក៏ដោយ ពួកគេត្រូវបានហាមប្រាមមិនឲ្យធ្វើការដើម្បីផលប្រយោជន៍ គាំទ្រ ឬប្រឆាំងគណបក្ស ឬបេក្ខជនគណបក្សណាមួយឡើង (មាត្រា៣៧)។ មាត្រា២ នៃច្បាប់លក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ចែងថា "មិនមាននិន្នាការជាមួយគណបក្សនយោបាយណាមួយ នៅក្នុងការអនុវត្តការងាររបស់ខ្លួនឡើយ" ។ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាចែងថា ពួកគេត្រូវប្រកាន់ឥរិយាបទអព្យាក្រឹត និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ (មាត្រា៥០) ផ្ទុយទៅវិញបែរជាចែងថាពួកគេត្រូវតែអព្យាក្រឹតនៅក្នុងសកម្មភាពនយោបាយ (មាត្រា៤)។ ចំពោះករណីនៃសមាជិកវិជ្ជាជីវៈតុលាការ មានការលើកជាសំណួរអំពីថា តើសាលក្រមដោយយុត្តិធម៌ និងមិនមានភាពលំអៀងទាំងឡាយ អាចធានាបានដោយរបៀបណា នៅក្នុងសំណុំរឿងក្តីដែលប្តឹងដោយគណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយ ប្រសិនបើចៅក្រមត្រូវបានអនុញ្ញាតឲ្យធ្វើជាសមាជិកសកម្មរបស់គណបក្សនយោបាយណាមួយ។

ចំពោះកងកម្លាំងសន្តិសុខ អ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងខាងសមាគម បានគូសបញ្ជាក់ថា "សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងនគរបាល អាចមាន [សិទ្ធិសេរីភាពខាងសមាគម] ដែលមានការរឹតត្បិតតាមផ្លូវច្បាប់។ ទោះជាយ៉ាងណាក៏ដោយ រាល់ការរឹតត្បិតណាមួយ ត្រូវតែគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់រដ្ឋ ជាអាទិ៍ ការរឹតត្បិតទូទៅ មិនត្រូវបានចាត់ទុកថាស្របច្បាប់ឡើយ។"[40]

វាគឺជាសិទ្ធិរបស់រដ្ឋ ដើម្បីដាក់ការរឹតត្បិតលើសកម្មភាពរបស់ "អ្នកដែលកាលពីពេលកន្លងមកបានរំលោភតួនាទីនៃអំណាចប្រតិបត្តិ ឬអំណាចនីតិបញ្ញត្តិ" នេះបើយោងតាមការសិក្សាស្រាវជ្រាវដោយ

[39] សេចក្តីប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ អនុម័តនៅថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៩៤។ សូមមើលគេហទំព័រ៖ http://www.ipu.org/Cnl-e/154-free.htm.

[40] របាយការណ៍លេខ A/HRC/20/27, កថាខណ្ឌ ៥៤។

សហភាពអន្តរសភាស្តីពីការបោះឆ្នោតដោយសេរី និងយុត្តិធម៌។[41] បទល្មើសបែបនេះ ត្រូវបានបរិយាយនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ក្នុងគន្ថីបួន មាតិកាទី៣ ជំពូកទី១ "ការប៉ះពាល់ដល់រដ្ឋបាលសាធារណៈដោយអ្នកតំណាងអាជ្ញាធរសាធារណៈ"។

**ការិយាល័យOHCHR សូមផ្តល់ជាអនុសាសន៍ឲ្យធ្វើការតាក់តែងមាត្រា១៨ ថ្មី នេះឡើងវិញ** ដូចខាងក្រោមនេះ៖

*១.ពលរដ្ឋទាំងពីរភេទ អាចធ្វើជាប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬធ្វើជាសមាសភាពនៃអង្គការដឹកនាំនៃគណបក្សនយោបាយបាន។*

*២. ប្រធាន អនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ មិនត្រូវជា៖*

*ក. បុគ្គលដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលលើសពីប្រាំឆ្នាំ ពីបទឧក្រិដ្ឋពាក់ព័ន្ធការប្រព្រឹត្តអំពើហឹង្សា ការញុះញង់ឲ្យស្អប់ខ្ពើម ឬការរំលោភអំណាចនីតិប្រតិបត្តិ ឬអំណាចនីតិបញ្ញត្តិ ដូចមានចែងក្នុងគន្ថីបួន មាតិកាទី៣ ជំពូកទី១នៃក្រមព្រហ្មទណ្ឌ លើកលែងតែ បុគ្គលនោះ ត្រូវបានលើកលែងទោស ឬរយៈប្រាំឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីថ្ងៃបានបំរើទោសចប់ ឬ*

*ខ. បុគ្គលដែលកាន់មុខតំណែង ឬចូលកាន់មុខតំណែងជាអ្នកដឹកនាំជាន់ខ្ពស់នៅក្នុងជួរកងទ័ព នគរបាល តុលាការ ឬស្ថាប័នរដ្ឋណាមួយ ដែលតម្រូវឲ្យត្រូវតែរក្សាអព្យាក្រឹតភាពនយោបាយ ភាពមិនលំអៀង និងឯករាជ្យភាពពីគណបក្សនយោបាយ។*

*៣. ប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវបាត់បង់នូវតួនាទីរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម៖*

*ក. សាមីខ្លួនទទួលមរណភាព។*

---

[41] Guy S. Goodwin-Gill, ការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ សហភាពអន្តរសភា, ទីក្រុងហ្សឺណែវ, ឆ្នាំ ២០០៦, ទំព័រ ១៣៧។

*ខ. សាមីខ្លួនបានសុំលាឈប់ជាលាយលក្ខអក្សរ។*

*គ. សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលលើសពីប្រាំឆ្នាំ ដោយគ្មានជម្រើសក្នុងការបង់ប្រាក់ពិន័យ ចំពោះបទឧក្រិដ្ឋពាក់ព័ន្ធការប្រព្រឹត្តអំពើហឹង្សា ការញុះញង់ឲ្យស្អប់ខ្ពើម លើកលែងតែទោសនោះត្រូវបានលើកលែងទោសដោយព្រះមហាក្សត្រ ឬ*

*ឃ. សាមីខ្លួនកាន់មុខតំណែង ឬចូលកាន់មុខតំណែងជាអ្នកដឹកនាំជាន់ខ្ពស់នៅក្នុងជួរកងទ័ព នគរបាល តុលាការ ឬស្ថាប័នរដ្ឋណាមួយ ដែលតម្រូវឲ្យត្រូវតែរក្សាអព្យាក្រឹតភាពនយោបាយ ភាពមិនលំអៀង និងឯករាជ្យភាពពីគណបក្សនយោបាយ។*

**មាត្រា១៩ ថ្មី**

ក្នុងរយៈពេលយ៉ាងយូរ ១៨០ (មួយរយប៉ែតសិប)ថ្ងៃ បន្ទាប់ពីគណបក្សនយោបាយត្រូវបានបង្កើតឡើងស្របតាមមាត្រា៩ នៃច្បាប់នេះ គណបក្សនយោបាយនោះ ត្រូវស្នើសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដើម្បីទទួលបានសុពលភាព និងអាចធ្វើសកម្មភាពបានដោយស្របច្បាប់ក្នុងឋានៈជានីតិបុគ្គល ដោយត្រូវមានសមាជិកយ៉ាងតិច ៤០០០ (បួនពាន់)នាក់ និងត្រូវបំពេញបែបបទ និងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ។

គណបក្សនយោបាយដែលមិនទទួលបានការចុះបញ្ជីស្របតាមបទប្បញ្ញត្តិនៃជំពូកនេះ មិនអាចធ្វើសកម្មភាពនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ។

**មតិយោបល់**: បទដ្ឋានសិទ្ធិមនុស្ស មិនបានតម្រូវ ហើយក៏មិនបានច្រានចោលការចុះបញ្ជីគណបក្សនយោបាយឡើយ។ របបនៃការចុះបញ្ជី គឺមិនមានភាពចាំបាច់សម្រាប់ការបង្កើត ឬការប្រតិបត្តិរបស់គណបក្សនយោបាយទេ ប៉ុន្តែប្រសិនជាមាន វាគួរតែជាកម្មវត្ថុនៃការអនុម័តយល់ព្រមជាមុនពីអាជ្ញាធរ[42] នេះបើតាមអ្នករាយការណ៍ពិសេស SRFOAA ដែលបានគូសបញ្ជាក់ថា សិទ្ធិសេរីភាពខាងសមាគម អនុវត្តដោយស្មើភាពគ្នាចំពោះសមាគមទាំងអស់ដែលមិនបានចុះបញ្ជី។[43] OSCE បានលើកឡើងថា ការចុះបញ្ជី អាចនឹងមានផលប្រយោជន៍ដល់គណបក្សនយោបាយ ដូច្នេះហើយវាអាច "សម

[42] របាយការណ៍លេខ A/68/299, កថាខណ្ឌ ៣១។

[43] របាយការណ៍លេខ A/HRC/20/27, កថាខណ្ឌ ៥៦។

ហេតុផល ដើម្បីតម្រូវឲ្យមានការចុះបញ្ជីគណបក្សនយោបាយជាមួយនឹងអាជ្ញាធររដ្ឋ។"[44]អត្ថប្រយោជន៍បែបនេះ អាចរួមបញ្ចូល ឧទាហរណ៍ ការការពារតាមផ្លូវច្បាប់នូវឈ្មោះ និងស្លាកសញ្ញារបស់គណបក្សលទ្ធភាពក្នុងការបើក និងរក្សាគណនីធនាគារ ឬទទួលបានថវិការដ្ឋ។ អត្ថប្រយោជន៍ដែលបានមកពីការចុះបញ្ជី គួរតែត្រូវបានចែងនៅក្នុងច្បាប់។ វិធីសាស្ត្រសិទ្ធិមនុស្សចំពោះករណីនេះ គឺទាក់ទងនឹងការលើកទឹកចិត្តឲ្យមានការចុះបញ្ជី តាមរយៈការផ្តល់ជារង្វាន់លើកទឹកចិត្ត ជាជាងការពង្រឹងអនុវត្តតាមរយៈការដាក់ទោសទណ្ឌ។

អ្នករាយការណ៍ពិសេស SRFOAA យល់ថាចំនួនមនុស្សអប្បបរមា អាចត្រូវបានតម្រូវ ដើម្បីបង្កើតគណបក្សនយោបាយមួយ ប៉ុន្តែនៅក្នុងកម្រិតមួយដែលមិនធ្វើឲ្យបុគ្គលទាំងឡាយបាក់ទឹកចិត្តក្នុងការចូលរួមក្នុងសកម្មភាពនយោបាយឡើយ។[45] បើនិយាយពីភាពសមហេតុផលនៃកម្រិតកំណត់ គឺវាអាស្រ័យទៅលើចំនួនមនុស្ស និងកាលៈទេសៈជាតិដទៃទៀត យន្តការសិទ្ធិមនុស្ស មិនបានកំណត់តួលេខដាច់ខាតថាចំនួនប៉ុន្មានទើបថាសមហេតុផលនោះឡើយ។ ដោយសារលទ្ធភាពនៃការយល់ច្រឡំ ឬការខិតខំប្រឹងប្រែងឥតប្រយោជន៍ក្នុងការអនុវត្តបទប្បញ្ញត្តិនេះ ដែលអាចនាំឲ្យមានការរំលោភសិទ្ធិសេរីភាពខាងសមាគម "ច្បាប់គួរតែចែងឲ្យបានច្បាស់ពីមធ្យោបាយ ដែលតាមរយៈនេះ ត្រូវតែបានបង្ហាញភស្តុតាងថាមានការគាំទ្រ"[46] - អាចតាមរយៈការចុះហត្ថលេខា ស្នាមមេដៃ ឬមធ្យោបាយដទៃផ្សេងទៀត ។

លក្ខខណ្ឌតម្រូវនៅក្នុងមាត្រា១៩ ថ្មីនេះ ដែលកំណត់សមាជិកភាពយ៉ាងតិច ៤000 នាក់ ក្នុងរយៈពេល១៨០ ថ្ងៃនៃការបង្កើត អាចបង្ករឧបសគ្គដល់ការចុះបញ្ជីគណបក្សនយោបាយ ជាពិសេសប្រសិនជាដូចមានចែងក្នុងកថាខណ្ឌទី២ ពួកគេមិនអាចធ្វើ "សកម្មភាពនយោបាយ" នៅមុនពេលចុះបញ្ជីបានឡើយ (សូមមើលខាងក្រោមនេះ)។ ប្រសិនជាមិនមានការបំភ្លឺបន្ថែមផ្សេងពីនេះនោះទេ វានឹងមិនកើតឡើងទេថា លក្ខខណ្ឌតម្រូវនេះ នឹងអាចជាប់តេស្តអំពីកត្តាសត្យានុម័ត និងភាពសមហេតុផលសម្រាប់ការរឹតត្បិត ដែលអាចដាក់ដោយស្របច្បាប់លើសិទ្ធិសេរីភាពខាងសមាគមបានឡើយ។

លក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជី ដើម្បីអាចអនុវត្ត"សកម្មភាពនយោបាយ"នេះ បាននាំឲ្យមានកង្វល់ជាច្រើនក្រោមច្បាប់សិទ្ធិមនុស្ស។ ពាក្យពេចន៍មិនច្បាស់លាស់ "សកម្មភាពនយោបាយ"

---

[44] គោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិគណបក្សនយោបាយ របស់ OSCE កថាខណ្ឌ ៦៥។ អាចរកបាននៅគេហទំព័រ៖ http://www.osce.org/odihr/77812?download=true.

[45] របាយការណ៍លេខ A/HRC/20/27, កថាខណ្ឌ ៥៤។

[46] គោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិគណបក្សនយោបាយ របស់ OSCE កថាខណ្ឌ ៧៨។

អាចសំដៅលើសកម្មភាពដែលស្ថិតក្នុងសិទ្ធិស្របច្បាប់របស់មនុស្សគ្រប់រូបក្នុងការអនុវត្ត ដោយមិនគិតថា សកម្មភាពនេះ ធ្វើឡើងតាមរយៈក្បាលម៉ាស៊ីនគណបក្សនយោបាយ រាប់ទាំងការរៀបចំ ឬការចូលរួមក្នុងកិច្ចពិភាក្សាដេញដោលលើបញ្ហានានា ដែលអាចមានចរិតលក្ខណៈនយោបាយ ធ្វើសកម្មភាពអប់រំពលរដ្ឋ ការកៀរគរការគាំទ្រ ឬប្រឆាំងនឹងគំនិតផ្តួចផ្តើម ឬសកម្មភាពដទៃផ្សេងទៀត ដែលស្ថិតក្នុងវិសាលភាពនៃសេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី ឬខាងសមាគម។ លើសពីនេះទៅទៀត គណបក្សនយោបាយថ្មីដែលកំពុងដំណើរការធ្វើការចុះបញ្ជី ការតម្រូវទៅលើចំនួនសមាជិកនោះ មិនគួរត្រូវបានរារាំងមិនឲ្យធ្វើ "សកម្មភាពនយោបាយ"នោះទេ ដែលបន្ទាប់ពីនេះការជ្រើសរើសសមាជិកភាពថ្មី អាចធ្វើបាន។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ឲ្យតាក់តែងឡើងវិញនូវមាត្រា១៩ ថ្មីនេះ ដូចខាងក្រោម៖ *គណបក្សនយោបាយដែលបានបង្កើតឡើងស្របតាមមាត្រា៩ នៃច្បាប់នេះ ត្រូវសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ តាមរយៈនីតិវិធី និងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ នៅពេលដែលគណបក្សនយោបាយ មានសមាជិកយ៉ាងតិច ៤,០០០ (បួនពាន់នាក់)។ ភស្តុតាងអំពីសមាជិកភាព ត្រូវបានបង្ហាញតាមរយៈការប្រមូលហត្ថលេខា ឬស្នាមមេដៃរបស់សមាជិកទាំងអស់។*

**មាត្រា២០.-**

គណបក្សនយោបាយ ត្រូវបំពេញបែបបទ និងល័ក្ខខ័ណ្ឌដូចខាងក្រោម៖

១. ពាក្យសុំចុះបញ្ជីគណបក្សនយោបាយ ត្រូវមានហត្ថលេខារបស់ប្រធានគណបក្សនយោបាយ។

២. ឈ្មោះជាអក្សរពេញ និងអក្សរកាត់ និងសញ្ញាសំគាល់របស់គណបក្សនយោបាយ។

៣. អាស័យដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ។

៤. ច្បាប់ដើមនៃលក្ខន្តិកៈគណបក្សនយោបាយចំនួនពីរច្បាប់។

៥. បទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយប្រសិនបើមាន។

៦. គោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗរបស់គណបក្សនយោបាយ។

៧. សេចក្តីថ្លែងការណ៍ជាលាយលក្ខអក្សររបស់គណបក្សនយោបាយស្តីពីការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងបទប្បញ្ញត្តិផ្សេងៗជាធរមាន និងគោលការណ៍នៃលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស។

៨. បញ្ជីឈ្មោះដោយមានអាយុ អាស័យដ្ឋាន និងស្នាមមេដៃរបស់សមាជិកទាំង ៤០០០នាក់ ដោយមានបញ្ជាក់លេខប័ណ្ណសមាជិកគណបក្ស និងកាលបរិច្ឆេទនៃការចូលសមាជិកភាពគណបក្សនយោបាយ។

៩. ជីវប្រវត្តិសង្ខេបរបស់ប្រធាន ឬស្ថាបនិកចំនួន ៣ នាក់យ៉ាងតិច ក្នុងមួយនាក់មួយច្បាប់ ដោយមានបិទរូបថតទំហំ ៤ គុណនឹង ៦ ។

១០. សេចក្តីប្រកាសអំពីគណនីធនាគារ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។

១១. បង្កាន់ដៃថ្លៃអាករចុះបញ្ជីគណបក្សនយោបាយមួយច្បាប់។ ថ្លៃអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៣.-**

ក្នុងករណីពិនិត្យឃើញថា សំណុំឯកសាររបស់គណបក្សនយោបាយណាមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយនិងច្បាប់នានាជាធរមាន ក្រសួងមហាផ្ទៃត្រូវធ្វើលិខិតឆ្លើយតបស្តីពីការយល់ព្រមឲ្យចុះបញ្ជី ផ្ញើជូនទៅសាមីគណបក្សនយោបាយនោះវិញ ដោយភ្ជាប់ជាមួយនូវលក្ខន្តិកៈមួយច្បាប់ ដែលមានចារបញ្ជាក់កាលបរិច្ឆេទនៃការចុះបញ្ជីគណបក្សនយោបាយ ដោយមានចុះហត្ថលេខា និងត្រារបស់ក្រសួងមហាផ្ទៃ។

**មាត្រា២៤.-**

ក្នុងករណីពិនិត្យឃើញថា សំណុំឯកសាររបស់គណបក្សនយោបាយ ដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់នានាជាធរមាន ក្រសួងមហាផ្ទៃ ត្រូវធ្វើលិខិតជូនដំណឹងផ្ញើជូនទៅសាមីគណបក្សនយោបាយនេះវិញ។ គណបក្សនយោបាយនោះ ត្រូវបំពេញបន្ថែមលើសំណុំឯកសារតាមលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃយ៉ាងយូរ ១៥ថ្ងៃ ចាប់ពីថ្ងៃទទួលលិខិតនេះ។ បើហួសរយៈពេលកំណត់

១៥ថ្ងៃនេះ ក្រសួងមហាផ្ទៃ ត្រូវធ្វើលិខិតមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយផ្ញើជូនទៅសាមីគណបក្សនយោបាយ។

**មតិយោបល់៖** ចំពោះការដែលថាគណបក្សនយោបាយមានតួនាទីដាច់ខាតក្នុងការធានាពហុនិយម និងការប្រព្រឹត្តទៅដ៏ត្រឹមត្រូវនៃលទ្ធិប្រជាធិបតេយ្យនោះ អ្នករាយការណ៍ពិសេស SRFOAA បានកត់សម្គាល់ថា "ការសន្មត់ដែលគាំទ្រដល់ការបង្កើតគណបក្សនយោបាយមួយ មានន័យថា ការសម្រេចអវិជ្ជមាន គួរតែត្រូវបានពន្យល់ហេតុផលឲ្យបានម៉ឺងម៉ាត់ ស្របតាមបទដ្ឋានដែលបានកំណត់ក្នុងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពាក់ព័ន្ធនឹងសមាមាត្រភាព និងភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ។[47] អាស្រ័យហេតុនេះ វាជាការសំខាន់ដែលថា មូលហេតុនៃការបដិសេធមិនយល់ព្រម ត្រូវតែបានសរសេរឲ្យច្បាស់លាស់ជាងនេះច្រើនថែមទៀត ដើម្បីឲ្យពួកគេអាចប្តឹងតវ៉ាទៅតុលាការបាន។ សូមមើលមតិយោបល់របស់ការិយាល័យOHCHR ក្នុងមាត្រា៣៨ ថ្មី ស្តីពីកាតព្វកិច្ចរបស់រដ្ឋ ក្នុងការផ្តល់ឲ្យមានស្ថាប័នឯករាជ្យ និងមិនលំអៀង រាប់ទាំងស្ថាប័នគ្រប់គ្រងការបោះឆ្នោត ដូចដែលបានពន្យល់ដោយអ្នករាយការណ៍ពិសេស SRFOAA។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ស្នើសុំបន្ថែមលក្ខខណ្ឌតម្រូវមួយ ក្រោមច្បាប់នេះថាលិខិតមិនយល់ព្រម ត្រូវបញ្ជាក់មូលហេតុឲ្យបានច្បាស់លាស់ថាហេតុអ្វីបានជាការចុះបញ្ជីត្រូវបានមិនយល់ព្រមដោយក្រសួងមហាផ្ទៃ។

**មាត្រា២៥.- ថ្មី**

គណបក្សនយោបាយណា ដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយ ដូចមានចែងក្នុងមាត្រា២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះមានសិទ្ធិប្តឹងទៅតុលាការកំពូល។

តុលាការកំពូល ត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងរបស់សាមីគណបក្សនយោបាយនោះ។

ក្រោយពីបានទទួលសេចក្តីសម្រេចរបស់តុលាការកំពូលដែលសម្រេចពីភាពត្រឹមត្រូវនៃខ្លឹមសារនៃសំណុំឯកសាររបស់គណបក្សនយោបាយនោះ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជីគណបក្សនយោបាយនោះភ្លាម តាមការកំណត់ដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ។

---

[47] របាយការណ៍លេខ A/68/299, កថាខណ្ឌ ៣២។

**មតិយោបល់:** មាត្រា២៥ ថ្មី អនុញ្ញាតឲ្យគណបក្សនយោបាយនោះមានសិទ្ធិប្ដឹងទៅតុលាការកំពូល ជាជាងការអនុវត្តនីតិវិធីធម្មតារបស់តុលាការ ដែលដំបូងគឺត្រូវដាក់ពាក្យបណ្ដឹងទៅសាលាដំបូង បន្ទាប់មកទៅសាលាឧទ្ធរណ៍ ហើយនៅចុងបញ្ចប់ទៅតុលាការកំពូលដែលជាតុលាការចេញសាលដីកាបិទផ្លូវតវ៉ា។ ការដែលតម្រូវឲ្យប្ដឹងដោយផ្ទាល់ទៅតុលាការកំពូល មិនអនុញ្ញាតឲ្យមានការដោះស្រាយវិវាទតាមបីដំណាក់កាល ដែលជាបទដ្ឋានអន្តរជាតិ និងដែលត្រូវបានកំណត់នៅក្នុងច្បាប់ស្ដីពីការរៀបចំអង្គការតុលាការនោះទេ។

**ការិយាល័យ OHCHR សូមផ្ដល់អនុសាសន៍ឲ្យ**តាក់តែងឡើងវិញនូវមាត្រា២៥ ថ្មី ដូចខាងក្រោមនេះ។

> *"គណបក្សនយោបាយណាដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយ ដូចមានចែងក្នុងមាត្រា២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះ មានសិទ្ធិប្ដឹងទៅសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។"*
>
> *តុលាការពាក់ព័ន្ធ ត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងរបស់សាមីគណបក្សនយោបាយនោះ។*
>
> *ក្រោយពីតុលាការចេញសេចក្ដីសម្រេចពីភាពត្រឹមត្រូវនៃខ្លឹមសារនៃសំណុំឯកសាររបស់គណបក្សនយោបាយនោះ ក្រសួងមហាផ្ទៃ ត្រូវចុះបញ្ជីគណបក្សនយោបាយនោះភ្លាម តាមការកំណត់ដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ។"*

**មាត្រា២៨.-**

រដ្ឋអាចផ្ដល់ប្រាក់ពីថវិកាជាតិស្មើៗគ្នាដល់គ្រប់គណបក្សនយោបាយ សម្រាប់តែប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

គណបក្សនយោបាយណាដែលមិនបានទទួលសន្លឹកឆ្នោតគាំទ្រចំនួន៣% នៃសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេស ឬមិនបានទទួលអាសនៈមួយក្នុងរដ្ឋសភា គណបក្សនយោបាយនោះ ត្រូវសងប្រាក់នោះគ្រប់ចំនួនមករដ្ឋវិញក្នុងរយៈពេល៣ខែយ៉ាងយូរ ចាប់ពីថ្ងៃប្រកាសលទ្ធផលជាស្ថាពរ នៃការបោះឆ្នោត។

**មាត្រា២៩.-ថ្មី**

គណបក្សនយោបាយ ត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយ ពីស្ថាប័នរដ្ឋ សមាគម អង្គការមិនមែនរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ វិទ្យាសាធារណៈ លើកលែងតែករណីដូចមានចែងក្នុងមាត្រា២៨ នៃច្បាប់នេះ។

គណបក្សនយោបាយ ត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយ ពីស្ថាប័នបរទេស ក្រុមហ៊ុនបរទេស ជនបរទេស ឬអង្គការដែលមានប្រភពហិរញ្ញប្បទានពីបរទេស។

**មតិយោបល់:** ការិយាល័យOHCHR ទទួលស្គាល់ពីសេចក្តីត្រូវការក្នុងការគ្រប់គ្រងថវិកាសម្រាប់គណបក្សនយោបាយ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងមិនលំអៀង។ ទោះជាយ៉ាងក៏ដោយ ការហាមឃាត់ក្នុងការទទួលវិភាគទានពីប្រភពហិរញ្ញប្បទានផ្សេងៗ ដូចបានលើកឡើងនេះ វាហាក់ដូចជាកំណត់លើការផ្តល់ហិរញ្ញប្បទានស្របច្បាប់ដល់ប្រាក់វិភាគទានសមាជិកភាព និងការចូលជាវិភាគទានពីបុគ្គលឯកជន និងក្រុមហ៊ុនកម្ពុជាក្នុងស្រុក។ ក្នុងន័យនេះ គណៈកម្មាធិការសិទ្ធិមនុស្ស បានកំណត់ថា "ការកម្រិតកំណត់សមហេតុផលទៅលើការចំណាយសម្រាប់យុទ្ធនាការ អាចនឹងត្រូវបានបញ្ជាក់មូលហេតុ កាលបើវាជាការចាំបាច់ ដើម្បីធានាថា ការជ្រើសរើសដោយសេរីរបស់អ្នកបោះឆ្នោត មិនត្រូវបានប៉ះពាល់ ឬដំណើរការប្រជាធិបតេយ្យ ត្រូវបានផ្លាស់ប្តូរដោយការចំណាយមិនសមាមាត្រក្នុងនាមជាបេក្ខជន ឬគណបក្សណាមួយឡើយ។"[48] អ្នករាយការណ៍ពិសេសSRFOAA បានបន្ថែមទៀតថា៖ "ការកម្រិតកំណត់ណាមួយលើលទ្ធភាពរបស់សមាគមក្នុងការទទួលបានហិរញ្ញប្បទានពីបរទេស គួរតែចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ហើយថាយុត្តិកម្មធម្មតាបានផ្តល់ដោយរដ្ឋ ដូចជាវិធានការប្រឆាំងភេរវកម្ម ការការពារអធិបតេយ្យរដ្ឋ ការបង្កើនប្រសិទ្ធភាពជំនួយ និងការពង្រឹងតម្លាភាព និងគណនេយ្យភាពនៃសង្គមស៊ីវិល ដែលជារឿយៗមិនបានបំពេញតាមបទដ្ឋានម៉ឺងម៉ាត់នេះឡើយ។"[49]

ក្នុងទិដ្ឋភាពនៃប្រជាពលរដ្ឋកម្ពុជាជាច្រើនដែលបានធ្វើចំណាកស្រុក ចំនួនធំនៃពលករចំណាកស្រុកកម្ពុជានៅបរទេស និងការដែលថាកម្ពុជាបានទទួលស្គាល់សញ្ជាតិពីរ ដូច្នេះពាក្យថា "បរទេស" និង "ជនបរទេស" គួរតែត្រូវបានកំណត់ឲ្យបានច្បាស់ ដើម្បីជៀសវាងការផាត់ចេញប្រជាពលរដ្ឋកម្ពុជា

---

[48] សេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស នៃកតិកាសញ្ញា ICCPR លេខ ២៥ កថាខណ្ឌ១៩។

[49] របាយការណ៍លេខ A/68/299, កថាខណ្ឌ ៥៤។

ដែលរស់នៅបរទេស មិនឲ្យផ្តល់វិភាគទាន ប្រសិនជាពួកគេចង់ផ្តល់នោះ។

ដោយមានសញ្ញាព្រមាននេះ បទប្បញ្ញត្តិនៃការផ្តល់ហិរញ្ញប្បទានពីប្រភពបរទេស ជាទូទៅត្រូវបានពិចារណាថាអាចទទួលយកបាន ហើយគឺជាការអនុវត្តទូទៅមួយ។ អនុសញ្ញាស្តីពីបទដ្ឋាននៃការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ សិទ្ធិ និងសេរីភាពបោះឆ្នោតក្នុងរដ្ឋជាសមាជិកនៃរដ្ឋឯករាជ្យ Commonwealth កំណត់ថា "អំណោយបរទេស រាប់ទាំងអំណោយដែលបានមកពីរូបវន្តបុគ្គល និងនីតិបុគ្គលបរទេសសម្រាប់បេក្ខជនគណបក្សនយោបាយ (សម្ព័ន្ធភាព) ការចូលរួមក្នុងការបោះឆ្នោត ឬចំពោះអង្គការសមាគមសាធារណៈដទៃទៀត ដោយផ្ទាល់ ឬដោយប្រយោល ឬក្នុងចរិតលក្ខណៈមួយទៀតទាក់ទងនឹង ឬស្ថិតក្រោមឥទ្ធិពល ឬការគ្រប់គ្រងដោយផ្ទាល់ពីបេក្ខជនគណបក្សនយោបាយ (សម្ព័ន្ធភាព) មិនត្រូវបានអនុញ្ញាតឡើយ។"[50]

ដោយយល់ឃើញថា គណបក្សនយោបាយ គឺជាយន្តមួយដ៏សំខាន់ ដែលតាមរយៈនេះ ប្រជាពលរដ្ឋប្រើសិទ្ធិរបស់ខ្លួនក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ ប្រភពហិរញ្ញប្បទាន អាចជាកង្វល់មួយ ប្រសិនបើប្រភពហិរញ្ញប្បទាននោះអាចធ្វើឲ្យប៉ះពាល់ ឬផ្លាស់ប្តូរទស្សនៈ អាទិភាព ឬទិដ្ឋភាពណាមួយផ្សេងទៀតនៃការងាររបស់គណបក្សមួយ។ ក្នុងន័យនេះ គេសង្កេតឃើញថា មិនមានការធានាបែបនេះទេ នៅក្នុងមាត្រា២៩ ថ្មី។ ទស្សនៈនេះ ត្រូវបានគាំទ្រដោយក្រុមប្រឹក្សាអឺរ៉ុប ដែលបើតាមក្រុមប្រឹក្សានេះ វិធានការនានាត្រូវបានចាត់ឡើងដោយរដ្ឋទាំងឡាយ ក្នុងការគ្រប់គ្រងអំណោយដល់គណបក្សនយោបាយ ដែលគួរតែបញ្ចូលទៅក្នុងវិធានជាក់លាក់មួយចំនួន ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍, ធានាតម្លាភាពនៃអំណោយ និងជៀសវាងអំណោយសម្ងាត់, ជៀសវាងការធ្វើឲ្យអន្តរាយដល់សកម្មភាពរបស់គណបក្សនយោបាយ និងធានាឯករាជ្យភាពនៃគណបក្សនយោបាយ។[51]

សូមមើលមតិយោបល់របស់ការិយាល័យOHCHR លើមាត្រា ៣៨ ថ្មី ស្តីពីកាតព្វកិច្ចរបស់រដ្ឋដើម្បីបង្កើតស្ថាប័នឯករាជ្យ និងមិនលំអៀង រួមបញ្ចូលទាំងស្ថាប័នគ្រប់គ្រងការបោះឆ្នោត ដូចដែលបានពន្យល់ដោយអ្នករាយការណ៍ពិសេស SRFOAA ។

---

[50] អនុសញ្ញាស្តីពីបទដ្ឋាននៃការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ សិទ្ធិ និងសេរីភាពបោះឆ្នោតក្នុងរដ្ឋជាសមាជិកនៃរដ្ឋឯករាជ្យ Commonwealth, គណៈកម្មការអឺរ៉ុបសម្រាប់លទ្ធិប្រជាធិបតេយ្យ តាមរយៈច្បាប់ (គណៈកម្មការទីក្រុងវឺនីស) មាត្រា ១២៣។

[51]សូមមើលអនុសាសន៍លេខ ៤ (ឆ្នាំ២០០៣) របស់គណៈកម្មាធិការរដ្ឋមន្ត្រី ជូនចំពោះរដ្ឋសមាជិក ស្តីពីវិធានរួមប្រឆាំងនឹងអំពើពុករលួយ នៅក្នុងការផ្តល់មូលនិធិដល់គណបក្សនយោបាយ, អនុម័តដោយគណៈកម្មាធិការរដ្ឋមន្ត្រី ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៣ មាត្រា ៣។ អាចរកបាននៅគេហទំព័រៈ http://www.coe.int/t/dg1/legalcooperation/economiccrime/cybercrime/cy%20activity%20interface2006/rec%202003%20(4)%20pol%20parties%20EN.pdf.

**ការិយាល័យ OHCHR សូមផ្ដល់អនុសាសន៍**ឲ្យមានការបង្ហាញអំពីលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ដើម្បីកំណត់ពាក្យ "បរទេស" នៅក្នុងវាក្យខ័ណ្ឌទី២ ដើម្បីកុំឲ្យមានការរារាំងដល់ពលរដ្ឋកម្ពុជាដែលកំពុងរស់នៅ ឬធ្វើការនៅក្រៅប្រទេស មិនឲ្យផ្ដល់វិភាគទានដល់គណបក្សនយោបាយមួយតាមការជ្រើសរើសរបស់ខ្លួន។ ការិយាល័យOHCHR សូមផ្ដល់អនុសាសន៍បន្ថែមទៀត ដោយស្នើឲ្យដាក់ជំនួសនៅក្នុងកថាខ័ណ្ឌទី២ "...អង្គការដែលមានប្រភពហិរញ្ញប្បទានពីបរទេស។" មកជាប្រយោគថា "*...អង្គការដែលប្រភពហិរញ្ញប្បទានតែមួយគត់របស់ខ្លួនបានមកពីបរទេស។*" លើសពីនេះទៀត ការិយាល័យOHCHR សូមបន្ថែមកថាខ័ណ្ឌទីប៣ ដែលប្រគល់តួនាទីទៅឲ្យស្ថាប័នមួយអព្យាក្រឹតដែលឯករាជ្យពីអង្គនីតិប្រតិបត្តិ ដែលមានការទទួលខុសត្រូវក្នុងការបង្កើតវិធានជាក់លាក់ ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ ធានាឲ្យមានតម្លាភាពនៃអំណោយ និងធានាឯករាជ្យភាព របស់គណបក្សនយោបាយ។

**មាត្រា៣៨.-ថ្មី**

គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សនយោបាយណាមួយបានឡើយ លើកលែងតែគណបក្សនោះ ត្រូវបានរំលាយដោយតុលាការ។

**មតិយោបល់**: សូមមើលមតិយោបល់របស់ការិយាល័យ OHCHR លើមាត្រា៦ ថ្មី និង មាត្រា ៣៨ ថ្មី។ ក្នុងគោលការណ៍ណែនាំរបស់ខ្លួនស្ដីបទបញ្ញាស្ដីគណបក្សនយោបាយ គណៈកម្មាធិការទីក្រុង Venice បញ្ជាក់យ៉ាងច្បាស់ថា សមាមាត្រភាព គួរតែបានធ្វើការថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្ន ហើយវិធានការហាមឃាត់លើគណបក្សនយោបាយ គួរតែត្រូវបានអនុវត្តក្នុងន័យតូចចង្អៀត។ ការរំលាយចោល គួរតែត្រូវបានអនុវត្ត ប្រសិនជាមិនអាចរកឃើញមានការរឹតត្បិតតិចជាងនេះទេនោះ។ ការរំលាយគណបក្សនយោបាយ ដោយផ្អែកលើសកម្មភាពនៃសមាជិកគណបក្ស ក្នុងលក្ខណៈជាបុគ្គលនោះ គឺមានវិសមិតភាពទៅនឹងការការពារ ដែលគួរតែស្របតាមគណបក្សថាជាសមាគម។ វិសមិតភាពនេះពង្រីកទៅដល់សកម្មភាពរបស់បុគ្គលនៃថ្នាក់ដឹកនាំគណបក្ស លើកលែងតែករណីដែលពួកគេបានបង្ហាញឲ្យឃើញថា បានធ្វើសកម្មភាពជាតំណាងរបស់គណបក្សទាំងមូល។[52]

**ការិយាល័យOHCHR សូមផ្ដល់អនុសាសន៍**ឲ្យរាប់បញ្ចូលប្រយោគខាងក្រោមនៅខាងចុងបញ្ចប់នៃមាត្រានេះ៖ "*ការរំលាយចោលគណបក្សនយោបាយ នឹងត្រូវបានអនុវត្តតែនៅក្នុងមធ្យោបាយចុងក្រោយតែប៉ុណ្ណោះ នៅពេលដែលកិច្ចខិតខំប្រឹងប្រែងទាំងអស់ផ្សេងទៀត ដើម្បីធានាអនុលោមភាពតាម*

[52] គោលការណ៍ណែនាំស្ដីពីបទប្បញ្ញត្តិគណបក្សនយោបាយ របស់ OSCE កថាខណ្ឌ ១០, ១៦។

*ច្បាប់នោះ ត្រូវបានប្រើអស់លទ្ធភាព។"*

**មាត្រា៣៨.- ថ្មី**

គ្រប់គណបក្សនយោបាយទាំងអស់ ត្រូវគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា។

ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តខុសទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃអាចចាត់វិធានការដូចខាងក្រោម ៖

- ចេញលិខិតជូនដំណឹងឲ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវក្នុងរយៈពេលមួយជាកំណត់។
- ធ្វើការព្រមានជាលាយលក្ខណ៍អក្សរ និងចាត់វិធានការបញ្ឈប់សកម្មភាពខុសច្បាស់ក្នុងករណីចាំបាច់។
- សម្រេចផ្អាកសកម្មភាពរបស់គណបក្សនយោបាយនោះជាបណ្តោះអាសន្នក្នុងរយៈពេលមួយជាកំណត់។
- ប្តឹងទៅតុលាការកំពូល ដើម្បីរំលាយគណបក្សនយោបាយនោះ ក្នុងករណីកំហុសមានលក្ខណៈធ្ងន់ធ្ងរ ។

**មតិយោបល់៖** ទោះបីជាមានតែតុលាការទេដែលមានសិទ្ធិអំណាចក្នុងរំលាយគណបក្សនយោបាយបាន ដូចមានចែងក្នុងមាត្រា៣៤ ថ្មីក៏ដោយ មាត្រា៣៨ ថ្មី អនុញ្ញាតឲ្យក្រសួងមហាផ្ទៃផ្អាកសកម្មភាពរបស់គណបក្សមួយ ផ្អែកលើមូលហេតុទូលំទូលាយ មានដូចជា "ប្រព្រឹត្តខុសទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា" ដែលគឺវាជាការទទួលខុសត្រូវរបស់តុលាការឯករាជ្យមួយជាអ្នកកំណត់។ ការមិនមានចែងអំពីលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់រយៈពេលនៃការផ្អាក "ជាបណ្តោះអាសន្ន" នូវគណបក្សនយោបាយ បានអនុញ្ញាតតាមមាត្រានេះ ផ្លាស់ប្តូរសិទ្ធិអំណាចផ្អាកសកម្មភាព ទៅអំណាចរំលាយគណបក្សនយោបាយ *តាមព្រឹត្តន័យ* ។ លើសពីនេះទៀត ភាពមិនច្បាស់លាស់នៅក្នុងឃ្លាចុងក្រោយដែលទាក់ទងនឹង "កំហុសដែលមានលក្ខណៈធ្ងន់ធ្ងរ" តម្រូវឲ្យមានការស្រាយបំភ្លឺ ប្រសិនជាមិនតម្រូវទេ ក្រសួងមហាផ្ទៃអាចនឹងមានឆន្ទានុសិទ្ធិក្នុងដាក់ញត្តិស្នើសុំរំលាយគណបក្សនយោបាយណាមួយ ដែលអាចនាំឲ្យមានការរំលោភសិទ្ធិរបស់សមាជិកគណបក្សនយោបាយណាមួយ ហើយជាឧបសគ្គធ្ងន់ធ្ងរដល់សកម្មភាពរបស់ពួកគេ។

ការបង្កើតការរឹតត្បិតលើសេរីភាពខាងសមាគម ដែលមានផលប៉ះពាល់សម្រាប់សេរីភាពក្នុងការការបញ្ចេញមតិ និងក្នុងការជួបប្រជុំដោយសន្តិវិធី វាមិនស្របទៅនឹងមាត្រា២២ កថាខ័ណ្ឌទី២ មាត្រា១៩ និងមាត្រា២១ នៃកតិកាសញ្ញា ICCPR នោះទេ។ ទន្ទឹមនឹងកតិកាសញ្ញា ICCPR មើលឃើញថា ការរឹតត្បិតការប្រើប្រាស់សេរីភាពខាងសមាគម អាចនឹងអនុញ្ញាតបានស្ថិតនៅក្រោមកាលៈទេសៈមួយចំនួន ការរឹតត្បិតនេះ ត្រូវការឲ្យមានលក្ខណៈសមាមាត្រទៅនឹងភាពចាំបាច់ ដែលបានកំណត់នៅក្នុងច្បាប់, ដែលចាំបាច់ដើម្បីដោះស្រាយការគំរាមកំហែងពិតប្រាកដមួយ, និងដែលត្រូវបានបញ្ចប់ទៅវិញនៅពេលដែលគោលដៅនេះត្រូវបានបំពេញ។[53] ការបង្កើតនេះ ក៏បានចោទឡើងជាសំណួរផងដែរអំពីភាពស្របគ្នារបស់វាជាមួយនឹងមាត្រា៣៥ នៃរដ្ឋធម្មនុញ្ញ ដែលកំណត់សិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប "ដើម្បីចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ ...នៃប្រទេសជាតិ" មាត្រា៤១ កំណត់ពីសេរីភាពក្នុងការបញ្ចេញមតិ និងក្នុងការជួបប្រជុំ ហើយមាត្រា៤២ ពីសេរីភាពក្នុងការបង្កើតសមាគម។

អ្នករាយការណ៍ SRFOAA ផ្តល់ការណែនាំនៅពេលណាដែលគណបក្សនយោបាយគួរតែត្រូវបានហាមឃាត់ដោយស្របច្បាប់។ បើយោងតាមអ្នករាយការណ៍ SRFOAA ការហាមឃាត់នេះ គួរតែត្រូវបានធ្វើឡើង "តែនៅពេលដែលគណបក្សនយោបាយមួយ ឬបេក្ខជនរបស់គណបក្សនយោបាយរបស់ខ្លួន ប្រើអំពើហឹង្សា ឬបញ្ចុះបញ្ចូលឲ្យមានអំពើហិង្សា ឬការស្អប់ខ្ពើមពូជសាសន៍ ឬជាតិ ឬសាសនាការ ដែលបង្កើតទៅជាការញុះញង់ឲ្យមានការរើសអើង អរិភាព ឬអំពើហិង្សា (មាត្រា ២០ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងក៏បានឆ្លុះបញ្ចាំងផងដែរនៅក្នុងមាត្រា៥ នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍) ឬនៅពេលដែលគណបក្សនយោបាយ អនុវត្តសកម្មភាព ឬទង្វើដែលបំផ្លិចបំផ្លាញសិទ្ធិ និងសេរីភាពដែលមានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ (មាត្រា៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)។"[54] ការិយាល័យ OHCHR បានកត់សម្គាល់ថា ការចែងយោងទៅអំពើហិង្សា ឬការញុះញង់ឲ្យមានការស្អប់ខ្ពើម មិនមានចែងនៅក្នុងច្បាប់ទេ។

ម្យ៉ាងវិញទៀត អ្នករាយការណ៍ពិសេស SRFOAA ផ្តល់អនុសាសន៍ថា ការទទួលខុសត្រូវក្នុងការគ្រប់គ្រងគណបក្សនយោបាយ គួរតែប្រគល់ឲ្យទៅស្ថាប័នឯករាជ្យមួយដែលមានជំនាញឯកទេសក្នុងបញ្ហានេះ។ នៅក្នុងរបាយការណ៍ឆ្នាំ២០០៣ របស់ខ្លួនទៅកាន់មហាសន្និបាតអ.ស.ប អ្នករាយការណ៍ពិសេស SRFOAA បានសង្កត់ធ្ងន់ថា៖ "រដ្ឋមានកាតព្វកិច្ចផ្តល់ឲ្យមានស្ថាប័នឯករាជ្យ និងមិន

---

[53] សូមមើលផ្នែកខាងលើស្តីពី "ការរឹតត្បិតដែលអនុញ្ញាត្តិលើសិទ្ធិមនុស្ស" ។

[54] របាយការណ៍លេខ A/68/299, កថាខណ្ឌ ៣៨។

លំអៀង រួមទាំងស្ថាប័នគ្រប់គ្រងការបោះឆ្នោត និងអាជ្ញាធរគ្រប់គ្រងលើសារព័ត៌មាន បន្ថែមពីលើប្រព័ន្ធតុលាការមួយឯករាជ្យ ក្នុងការធានាថាដំណើរការបោះឆ្នោត មិនត្រូវបានគេកេងប្រវ័ញ្ច ដែលនាំឲ្យមានការប្រកួតប្រជែងមិនស្មើគ្នាសម្រាប់គណបក្សនយោបាយណាមួយឡើយ។ ដើម្បីឲ្យមានប្រសិទ្ធភាពស្ថាប័នគ្រប់គ្រង គួរតែឯករាជ្យពីអំណាចប្រតិបត្តិ... ទាំងនេះគឺជាលក្ខខណ្ឌសំខាន់សម្រាប់ការគោរពសិទ្ធិសេរីភាពខាងសមាគមនៅក្នុងបរិបទនៃការបោះឆ្នោត"។[55] ក្រសួងមហាផ្ទៃ គឺជាផ្នែកមួយនៃអង្គនីតិប្រតិបត្តិ ដូច្នេះហើយស្ថាប័ននេះ មិនមែនជាស្ថាប័នឯករាជ្យ ដែលត្រូវប្រគល់មុខងារគ្រប់គ្រងដ៏សំខាន់នេះឲ្យនោះទេ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ថា មាត្រា៣៨ ថ្មីត្រូវតាក់តែងឡើងវិញដើម្បីផ្តល់សិទ្ធិអំណាចតែទៅលើតុលាការ ដែលមានសិទ្ធិអំណាចក្នុងការដាក់ទណ្ឌកម្មដល់គណបក្សនយោបាយសម្រាប់ការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ហើយក៏គួរតែចែងលម្អិតអំពីបទល្មើសធ្ងន់ធ្ងរជាក់លាក់ ដែលអាចនាំឲ្យមានការដាក់ទោសទណ្ឌ ដោយយោងតាមបទប្បញ្ញត្តិពាក់ព័ន្ធនានានៃក្រមព្រហ្មទណ្ឌ។ ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍បន្ថែមទៀតថា ភារកិច្ចក្នុងការគ្រប់គ្រងគណបក្សនយោបាយ គួរតែបានប្រគល់ឲ្យទៅស្ថាប័ន គ្រប់គ្រងការបោះឆ្នោតឯករាជ្យ។

**មាត្រា៣៩.- ថ្មី**

ត្រូវផាកពិន័យជាប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន)រៀល ដោយក្រសួងមហាផ្ទៃចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៣១ នៃច្បាប់នេះ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀត ផាកពិន័យជាប្រាក់ទ្វេមួយជាពីរ ហើយក្រសួងមហាផ្ទៃ អាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្ន ក្នុងរយៈពេលមួយជាកំណត់។

**មាត្រា៤០.- ថ្មី**

គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ ដោយក្រសួងមហាផ្ទៃ ចំនួន ២០ ០០០ ០០០ (ម្ភៃលាន)រៀល។ ក្នុងករណីវិភាគទានដែលគណបក្សនយោបាយបានទទួលដោយល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ មានតម្លៃលើសពី ២០ ០០០ ០០០ (ម្ភៃលាន)រៀល ត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃតម្លៃនៃ

---

[55] A/68/299, para. 41.

វិភាគទាននោះ។ ក្រសួងមហាផ្ទៃ អាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្ន ក្នុងរយៈពេលមួយជាកំណត់។

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀត ត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃប្រាក់ពិន័យលើកមុខ ហើយក្រសួងមហាផ្ទៃអាចប្តឹងរំលាយគណបក្សនយោបាយនោះទៅតុលាការកំពូល។

**មតិយោបល់៖** ដូចបានបញ្ជាក់ទាក់ទងទៅនឹងមាត្រា ៣៨ ថ្មី ពាក្យពេចន៍មិនច្បាស់លាស់ដែលមាននៅក្នុងមាត្រា ៣៩ ថ្មី និងមាត្រា៤០ ថ្មី មិនបានកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការផ្អាកសកម្មភាពស្របច្បាប់របស់គណបក្សមួយដោយក្រសួងមហាផ្ទៃ ឬកំណត់ពេលវេលាសម្រាប់ការផ្អាកនេះឡើយ ដែលអាចនាំឲ្យមានការរំលាយ*តាមព្រឹត្តន័យ* ដោយមិនមានការត្រួតពិនិត្យរបស់តុលាការ។ ដូច្នេះ ការនេះអាចនាំឲ្យមានការរំលោភបំពានលើសិទ្ធិរបស់សមាជិកគណបក្សនយោបាយណាមួយ និងបង្ករឧបសគ្គធ្ងន់ធ្ងរដល់សកម្មភាពរបស់ពួកគេ។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ឲ្យកែសម្រួលមាត្រា៣៩ ថ្មី និងមាត្រា៤០ ថ្មី ដើម្បីផ្តល់អំណាចឲ្យតែតុលាការដែលមានសិទ្ធិអំណាចក្នុងការផាកពិន័យ និងដាក់ទណ្ឌកម្មដល់គណបក្សនយោបាយដែលប្រព្រឹត្តបទល្មើសអ្វីមួយ។

**មាត្រា៤១.- ថ្មី**

ត្រូវផាកពិន័យជាប្រាក់ចំនួន ៣ ០០០ ០០០ (បីលាន)រៀល ដោយក្រសួងមហាផ្ទៃចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៥ និងកថាខណ្ឌទី២ មាត្រា១៥ នៃច្បាប់នេះ។

**មតិយោបល់៖** សូមមើលមតិយោបល់ និងអនុសាសន៍សម្រាប់មាត្រា៣៩ ថ្មី និងមាត្រា៤០ ថ្មី។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ឲ្យធ្វើការកែសម្រួលមាត្រា៤១ ថ្មី ដើម្បីផ្តល់អំណាចឲ្យតែតុលាការមានសិទ្ធិអំណាច ក្នុងការផាកពិន័យ និងដាក់ទោសទណ្ឌដល់គណបក្សនយោ បាយដែលប្រព្រឹត្តបទល្មើសអ្វីមួយ។

**មាត្រា៤២.- ថ្មី**

ត្រូវពិន័យជាប្រាក់ចំនួន ១០ ០០០ ០០០ (ដប់លាន)រៀល ដល់ ២០ ០០០ ០០០ (ម្ភៃលាន)រៀល និង/ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ)ខែ ដល់ ០១(មួយ)ឆ្នាំ ចំពោះជនណាដែលបានប្រព្រឹត្តករណីណាមួយដូចខាងក្រោមនេះ៖

១- បន្តគ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដែលក្រសួងមហាផ្ទៃមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយ។

២- បន្តគ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដែលតុលាការបានសម្រេចរំលាយជាស្ថាពរ។

៣- បន្តគ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដោយមិនបានសុំចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយក្នុងរយៈពេលលើសពី ១៨០(មួយរយប៉ែតសិប)ថ្ងៃ គិតចាប់ពីថ្ងៃធ្វើការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការបណ្តោះអាសន្នដូចមានចែងក្នុងមាត្រា៩នៃច្បាប់នេះ។

៤- នៅតែបន្តធ្វើសកម្មភាពក្នុងនាមគណបក្សនយោបាយ ទោះជាមានសេចក្តីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះក៏ដោយ។

៥- នៅតែបន្តបើកទីស្នាក់ការគណបក្សនយោបាយខ្លួន ទោះជាមានសេចក្តីសម្រេចស្ថាពររបស់តុលាការសម្រេចរំលាយគណបក្សនយោបាយនោះក៏ដោយ។

**មតិយោបល់៖** ដោយពិចារណាថា ការមិនយល់ព្រមចុះបញ្ជីដោយក្រសួងមហាផ្ទៃ គឺជាប្រធានបទដែលស្ថិតក្នុងកម្មវត្ថុនៃការបណ្តឹងឧទ្ធរណ៍ទៅតុលាការ ការដាក់ទោសទណ្ឌទៅលើបុគ្គល មិនគួរត្រូវបានអនុវត្តរហូតដល់ដំណើរការបណ្តឹងឧទ្ធរណ៍ត្រូវបិទបញ្ចប់។ សូមមើលមតិយោបល់របស់ការិយាល័យ OHCHR លើមាត្រា១៩ ថ្មី មាត្រា៣៩ ថ្មី និងមាត្រា៤០ ថ្មី។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ថា ការចុះបញ្ជី គួរតែត្រូវបានលើកទឹកចិត្តតាមរយៈរង្វាន់លើកទឹកចិត្ត ជាជាងតាមរយៈការទោសទណ្ឌកម្មសម្រាប់ការមិនចុះបញ្ជី។ សូមមើលអនុសាសន៍របស់ការិយាល័យ OHCHR លើមាត្រា១៩ ថ្មី។ ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ផងដែរឲ្យមានការតាក់តែងឡើងវិញនូវកថាខណ្ឌទី១ ដែលមានសេចក្តីថា ៖ "*បន្តគ្រប់គ្រង ឬដឹកនាំគណបក្ស*

*នយោបាយ ដែលការមិនយល់ព្រមចុះបញ្ជីរបស់គណបក្សនយោបាយទាំងនោះ ដោយក្រសួងមហាផ្ទៃ ត្រូវបានតម្កល់ដោយតុលាការកំពូល។"*

**មាត្រា៤៣.- ថ្មី**

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាទៅតុលាការកំពូលក្នុងអំឡុងពេល ៣០(សាមសិប)ថ្ងៃ គិតពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចនេះ។ ក្នុងអំឡុងពេលនៃការប្តឹងតវ៉ា និងអំឡុងពេលនៃការដោះស្រាយបណ្តឹងតវ៉ា សេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ មិនមានអានុភាពអនុវត្តឡើយ លើកលែងតែសេចក្តីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយជាបណ្តោះអាសន្ន។

**មតិយោបល់៖** សូមមើលមតិយោបល់របស់ការិយាល័យ OHCHR លើមាត្រា២៥ ថ្មី និងមាត្រា ៤០ថ្មី។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍**ឲ្យធ្វើការកែសម្រួលមាត្រានេះដូចខាងក្រោមនេះ៖ *"... អាចប្តឹងឧទ្ធរណ៍ទៅកាន់សាលាដំបូងក្នុងរយៈពេល៣០ថ្ងៃ គិតពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចនេះ ។ ករណីនេះ អាចនឹងត្រូវបានប្តឹងឧទ្ធរណ៍បន្តទៅសាលាឧទ្ធរណ៍ និងតុលាការកំពូល ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។ នៅក្នុងដំណាក់កាលនីមួយៗ តុលាការសាមីត្រូវចេញសាលក្រមក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីការដាក់បណ្តឹងឧទ្ធរណ៍។ នៅក្នុងអំឡុងពេលនៃការប្តឹងតវ៉ា និងនៃការដោះស្រាយបណ្តឹងតវ៉ា សេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ មិនមានប្រសិទ្ធភាពអនុវត្តឡើយ។"*

**មាត្រា៤៤.- ថ្មី**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៦ថ្មី និងមាត្រា៧ នៃច្បាប់នេះ តុលាការអាចសម្រេចដូចខាងក្រោម៖

- ផ្អាកសកម្មភាពគណបក្សនយោបាយនោះក្នុងរយៈពេលមិនលើសពី ៥ឆ្នាំ។
- រំលាយគណបក្សនយោបាយនោះ។

**មតិយោបល់៖** សូមមើលមតិយោបល់របស់ការិយាល័យOHCHR ត្រង់មាត្រា ៦ ថ្មី និងមាត្រា ៣៤ ថ្មី និងមាត្រា៣៨ ថ្មី។ នៅក្នុងគោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិគណបក្សនយោបាយ គណៈ

កម្មាធិការទីក្រុង Venice បញ្ជាក់យ៉ាងច្បាស់ថា សមាមាត្រភាព គួរតែត្រូវបានថ្លឹងថ្លែងដោយប្រុងប្រយ័ត្ន ហើយវិធានហាមប្រាមគួរតែបានអនុវត្តនៅក្នុងន័យចង្អៀត។[56]នៅក្នុងន័យនេះ ការរំលាយគណបក្សនយោបាយ គួរតែត្រូវបានអនុវត្តតែករណីប្រសិនបើមធ្យោបាយរឹតត្បិតតិចជាងនេះ មិនត្រូវបានរកឃើញ។ ម្យ៉ាងវិញទៀត ការរំលាយគណបក្សនយោបាយផ្អែកលើសកម្មភាពរបស់សមាជិកគណបក្សនយោបាយ ក្នុងលក្ខណៈជាបុគ្គលនោះ គឺមានវិសមិតភាពទៅនឹងការការពារដែលគួរតែត្រូវបានផ្តល់ឲ្យគណបក្សថាជាសមាគម។ វិសមិតភាពនេះ ពង្រីកទៅដល់សកម្មភាពរបស់បុគ្គលជាថ្នាក់ដឹកនាំគណបក្សនយោបាយ លើកលែងតែករណីដែលពួកគេបានបង្ហាញឲ្យឃើញថា បានធ្វើសកម្មភាពជាតំណាងរបស់គណបក្សទាំងមូល។[57]

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ឲ្យពិនិត្យឡើងវិញអំពីការដាក់ទណ្ឌកម្ម ក្នុងមាត្រានេះ ដើម្បីធានាឲ្យមានឃ្លាខាងក្រោមនេះនៅខាងចុងបញ្ចប់នៃមាត្រានេះ៖ *"មុននឹងសម្រេចលើវិធានការណ៍មួយ តុលាការត្រូវកំណត់ថា តើការដាក់ទណ្ឌកម្មនេះ គឺជាការចាំបាច់ដើម្បីសម្រេចគោលដៅរបស់ខ្លួន, ថាតើវិធានការណ៍រឹតត្បិតតិចជាងនេះ អាចត្រូវបានប្រើដើម្បីសម្រេចគោលដៅដែលចង់បានឬទេ និងថាតើវិធានការណ៍នេះមានលក្ខណៈសមាមាត្រទៅនឹងគោលដៅ ស្វែងរកឲ្យសម្រេចនេះឬទេ។ វិធានការណ៍រឹតត្បិតតិចតួចបំផុត ជានិច្ចកាល ត្រូវតែត្រូវបានពិចារណា។"*

**មាត្រា៤៥.- ថ្មី**

តុលាការដែលមានសមត្ថកិច្ច ដើម្បីពិនិត្យលើបណ្តឹងនានាដោយអនុវត្តតាមច្បាប់នេះ គឺតុលាការកំពូល។ ដោយឡែកចំពោះមាត្រា៤២ថ្មី នៃច្បាប់នេះ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

តំណាងមហាអយ្យការអមតុលាការកំពូល ត្រូវចូលរួមសុំឲ្យមានការគោរពច្បាប់ នៅក្នុងពេលដែលមានបណ្តឹងដាក់ជូនតុលាការកំពូលពិនិត្យ។

ក្នុងករណីដែលគណបក្សនយោបាយត្រូវបានរំលាយ តុលាការអាចសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំនៃគណបក្សនយោបាយនោះ សម្រាប់រយៈពេល ០៥(ប្រាំ)ឆ្នាំបាន។

---

[56] សូមមើលផ្នែកខាងលើស្តីពី "ការរឹតត្បិតដែលអនុញ្ញាតិលើសិទ្ធិមនុស្ស" ។"

[57] គោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិគណបក្សនយោបាយ របស់ OSCE កថាខណ្ឌ ១០, ១៦។

តុលាការកំពូល ត្រូវសម្រេចសេចក្តីលើអង្គហេតុ និងអង្គច្បាប់ ដោយសភាពេញអង្គ។ សាលដីការបស់តុលាការកំពូល ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

**មតិយោបល់៖** តាមរយៈប្រយោគ "ដោយឡែកចំពោះមាត្រា៤២ ថ្មី នៃច្បាប់នេះ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន" មាត្រា៤៥ ថ្មី ដាក់ការអនុវត្តន៍មាត្រាតែមួយគត់នៅក្នុងច្បាប់នេះទៅ "ក្រមនីតិវិធីព្រហ្មទណ្ឌ" ជាធរមាន។ ការសន្មត់នេះ យោងទៅលើនីតិវិធីដែលបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងពីកិច្ចធានាឲ្យមានការការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដូចដែលបានតម្រូវនៅក្នុងកតិកាសញ្ញាICCPR។ បើដូច្នេះ ក្រមនេះ គួរតែត្រូវបានរៀបរាប់ឲ្យបានជាក់លាក់។ ការកម្រិតកំណត់អំពីការអនុវត្តក្រមនេះចំពោះមាត្រាមួយនៃច្បាប់នេះ អាចនាំឲ្យមានការកំណត់អំពីវិធានការធានាដល់ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ ការហាមឃាត់នៅក្នុងវាក្យខ័ណ្ឌទី៣ នេះ អាចរារាំងបុគ្គលមិនឲ្យធ្វើសកម្មភាពនយោបាយរយៈពេលរហូតដល់ទៅប្រាំឆ្នាំ ដែលនៅពេលគិតអំពីភាពមិនច្បាស់លាស់នៃ "កំហុសធ្ងន់ធ្ងរ" ដែលអាចនាំទៅដល់ការរំលាយដូចមានចែងក្នុងមាត្រា៣៨ ថ្មី អាចត្រូវបានពិចារណារយៈពេលវែងពេក និងមិនសមមាត្រទៅនឹង "កំហុស" ។ សូមមើលផងដែរនូវមតិយោបល់របស់ការិយាល័យOHCHR លើមាត្រា២៥។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ឲ្យដាក់ជំនួសកថាខ័ណ្ឌទី១ នៃមាត្រានេះ នូវប្រយោគដូចខាងក្រោមនេះ៖ "*គណបក្សនយោបាយណាដែលការចុះបញ្ជីគណបក្សនយោបាយ មិនត្រូវបានយល់ព្រម មានសិទ្ធិប្តឹងឧទ្ធរណ៍ទៅតាមនីតិវិធីដែលបានកំណត់ឡើងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមានការធានានូវការជំនុំជម្រះប្រកបដោយយុត្តិធម៌។*"

**មាត្រា៤៨.- ថ្មី**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន គណបក្សនយោបាយទាំងអស់ដែលត្រូវបានបង្កើត និងបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបន្តសុពលភាព និងអាចធ្វើសកម្មភាពស្របតាមច្បាប់នេះ និងច្បាប់ជាធរមានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែគណបក្សនយោបាយទាំងនេះ ត្រូវបំពេញសំណុំបែបបទធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃយ៉ាងយូរ គិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន។

**មតិយោបល់៖** មាត្រា១៨ ថ្មី នៃសេចក្តីស្នើច្បាប់វិសោធនកម្មផ្តល់ឲ្យគណបក្សនយោបាយរយៈពេល ៩០ ថ្ងៃ ដើម្បីតំណែងប្រធាន ទន្ទឹមនេះមាត្រា១៩ ថ្មី អនុញ្ញាតរយៈពេល ១៨០ ថ្ងៃ ដើម្បីអនុវត្តតាមសេចក្តីតម្រូវផ្សេងទៀតសម្រាប់*ការចុះបញ្ជី* ។

**ការិយាល័យOHCHR សូមផ្តល់អនុសាសន៍**ឲ្យមានការពង្រីករយៈពេលក្នុងអំឡុងពេលដែលគណបក្សនយោបាយមួយត្រូវសំណុំបែបបទធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់ ឲ្យមានរយៈពេលដូចគ្នាគឺ១៨០ ថ្ងៃត្រូវបានអនុញ្ញាតចំពោះគណបក្សនយោបាយថ្មី។ ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍បន្ថែមទៀតថា ពាក្យ "ធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់" ត្រូវបានបញ្ជាក់ឲ្យច្បាស់លាស់ តាមរយៈការចែងយោងទៅមាត្រាជាក់លាក់នៅក្នុងច្បាប់ដែលកំណត់នីតិវិធីសម្រាប់ការធ្វើ និយ័តកម្ម។

**មាត្រា៤៩.- ថ្មី**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

**មតិយោបល់៖** មាត្រា ៤៩ ថ្មី ផ្ទុយនឹងឋានៈច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលមានចែងនៅក្នុងសន្ធិសញ្ញាដែលផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា រដ្ឋធម្មនុញ្ញ និងច្បាប់ដែលបានអនុម័តដោយសភា។ នៅក្នុងការគោរពសន្ធិសញ្ញាដែលបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា មាត្រា២៧ នៃអនុសញ្ញាក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា បានចែងថា "រដ្ឋភាគីមួយ មិនអាចចែងបទបញ្ញត្តិនៃច្បាប់ផ្ទៃក្នុងរបស់ខ្លួនជាយុត្តិកម្មសម្រាប់ការខកខានរបស់ខ្លួនក្នុងការអនុវត្តសន្ធិសញ្ញាមួយឡើយ។" លើសពីនេះទៀត មាត្រា២ កថាខ័ណ្ឌទី២ នៃកតិកាសញ្ញាICCPR ដែលភ្ជាប់កាតព្វកិច្ចអនុវត្តដល់ប្រទេសកម្ពុជា តម្រូវឲ្យរដ្ឋភាគី "ចាត់វិធានការចាំបាច់... ដើម្បីអនុម័តវិធានការច្បាប់ដូចនេះ ឬវិធានការផ្សេងទៀត ដែលអាចជាវិធានការចាំបាច់ ដើម្បីផ្តល់ប្រសិទ្ធភាពអនុវត្តដល់សិទ្ធិដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញា។" មាត្រាជាច្រើននៃច្បាប់នេះ មានលក្ខណៈប្រទាំងប្រទើសជាមួយបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិសេរីភាពខាងសមាគម និងក្នុងការបញ្ចេញមតិ ដែលភ្ជាប់កាតព្វកិច្ចអនុវត្តដល់ប្រទេសកម្ពុជា ដូចដែលបានពន្យល់នៅក្នុងមតិយោបល់ខាងលើ។ ដូច្នេះ ការអនុវត្តយ៉ាងតឹងរឹងនៃមាត្រា៤៩ ថ្មី នៃច្បាប់នេះ នឹងអាចនាំឲ្យមានការរំលោភបំពានលើច្បាប់អន្តរជាតិ។

មាត្រានេះក៏បានលើកជាបញ្ហាផងដែរ អំពីឋានៈនៃច្បាប់នេះទាក់ទងទៅនឹងច្បាប់ផ្សេងទៀត ច្បាប់ពិសេស ច្បាប់អង្គិន ដូចជារដ្ឋធម្មនុញ្ញ ដែលក្នុងនោះមានចែងអំពីសិទ្ធិមនុស្សជាមូលដ្ឋាន។ ភាពផ្ទុយគ្នាពីច្បាប់អន្តរជាតិដែលមានចែងនៅក្នុងច្បាប់នេះ ក៏ហាក់ដូចជាផ្ទុយផងដែរទៅនឹងរដ្ឋធម្មនុញ្ញ

របស់កម្ពុជា។ បញ្ហាជាច្រើនខាងនីតិវិធី គ្របដណ្ដប់នៅក្រោមច្បាប់នេះ ក៏មានភាពប្រទាំងប្រទើសផង ដែរជាមួយក្រមនីតិវិធីព្រហ្មទណ្ឌ។

**ការិយាល័យOHCHR សូមផ្ដល់អនុសាសន៍**ឲ្យមានការពិនិត្យជាទូទៅឡើងវិញ ដោយមានការពិគ្រោះយោបល់លើខ្លឹមសារនៃសេចក្ដីព្រាងច្បាប់នេះ ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងសេចក្ដីវិភាគនេះ ធ្វើដូច្នេះគឺដើម្បីបង្ការភាពប្រទាំងប្រទើសគ្នាដូចដែលបានបរិយាយសង្ខេបនៅក្នុងមតិយោបល់កន្លងមក។

**មាត្រា៥០.- ថ្មី**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់។

**មតិយោបល់**: ទោះជាមាត្រានេះ សំដៅថែងពីការចូលជាធរមាននៃច្បាប់វិសោធនកម្មនេះក្ដី ការិយាល័យOHCHR កត់សម្គាល់ថាច្បាប់វិសោធនកម្មច្បាប់នេះ ក៏ត្រូវបានកំណត់ផងដែរថា "ជាការប្រញាប់"។ ការកំណត់អំពីច្បាប់មួយប្រកាសជា "ការប្រញាប់" ដោយអង្គនីតិប្រតិបត្តិ មិនអាចនឹងមានលើកជាកង្វល់អំពីសិទ្ធិមនុស្សឡើយ នៅក្នុងអង្គរបស់ខ្លួនឯង ប្រសិនជាការកំណត់នោះត្រូវបានទទួលយកសម្រាប់ការជម្រុញឲ្យឆាប់រហ័យ តាមរយៈដំណើរការដែលធានាឲ្យមានការចូលរួមជាសាធារណៈ និងការជជែកពិភាក្សា។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់វាក្យស័ព្ទនេះ ដើម្បីគៀចវេសពីដំណើរការពិគ្រោះយោបល់នោះនោះ គឺជាហេតុផលសម្រាប់ការព្រួយបារម្ភ ជាពិសេសនៅពេលដែលកម្មវត្ថុមានលក្ខណៈចម្រូងចម្រាស ប៉ះពាល់ដោយផ្ទាល់ដល់គណបក្សនយោបាយទាំងឡាយដែលត្រូវអនុវត្តច្បាប់នេះ ហើយមិនមានហេតុផលជាភស្តុតាងដែលថែងអំពីការដែលត្រូវប្រកាសជាការប្រញាប់នេះ។

- ចប់ -